00626033

F14

**នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

**សំណុំរឿងលេខ៖** ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ត.ក

**ដាក់ទៅ៖** អង្គជំនុំជម្រះតុលាការកំពូល

**ថ្ងៃដាក់៖** ថ្ងៃទី១៨ ខែ វិច្ឆិកា ឆ្នាំ២០១០

**ភាគីអ្នកដាក់៖** សហមេធាវីជាតិការពារក្តីលោក **កាំង ហ្កេកអ៊ាវ** ហៅ "**ឌុច**"

**ភាសាដើម៖** **ភាសាខ្មែរ**

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ស្នើដោយភាគីអ្នកដាក់តម្កល់៖ **សាធារណៈ**:

ចំណាត់ថ្នាក់សម្រេចដោយសហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះ៖

លក្ខន្តិកៈនៃចំណាត់ថ្នាក់៖

ការពិនិត្យចំណាត់ថ្នាក់បណ្តោះអាសន្នឡើងវិញ៖

ឈ្មោះមន្ត្រីទទួលបន្ទុកផ្នែកសំណុំរឿងនិងឯកសារ៖

ហត្ថលេខា៖

**ឯកសារដើម**
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 18 / 11 / 2010
ម៉ោង (Time/Heure): 14:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

---

**សារណារបស់សហមេធាវីការពារក្តីជនជាប់ចោទ កាំង ហ្កេកអ៊ាវ ហៅ "ឌុច"**
**អំពីបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ របស់អង្គជំនុំជម្រះ**
**សាលាដំបូង**

---

**អ្នកដាក់ឯកសារ៖**

**សហមេធាវីការពារក្តីជនជាប់ចោទ**

**កាំង ហ្កេកអ៊ាវ** ហៅ "**ឌុច**"

មេធាវី **ការ សាវុត្ថ**

មេធាវី **កង ឫទ្ធារី**

**អ្នកទទួលឯកសារ៖**

**អង្គជំនុំជម្រះតុលាការកំពូល**

ចៅក្រម **គង់ ស្រ៊ឹម** ប្រធាន

ចៅក្រម **Motoo NOGUCHI**

ចៅក្រម **ស៊ុន វិទ្ធ**

ចៅក្រម **សោម សិរីវឌ្ឍ**

ចៅក្រម **C.N.JAYASINGHE**

ចៅក្រម **A. KLONOWIECKA-MILART**

ចៅក្រម **យ៉ា ណារិន**

00626034

សំណុំរឿងលេខ: ០០១/១៨-០៧-២០០៧-អ.វ.ត.ក /អ.ជ.ត.ក

F114

**<u>សហព្រះរាជអាជ្ញា</u>**

លោកស្រី **ជា លាង**

លោក **Andrew CAYLEY**

**<u>មេធាវីដើមបណ្តឹងរដ្ឋប្បវេណី</u>**

| | | |
|---|---|---|
| មេធាវី គង់ ពិសី | មេធាវី Silke STUDZINSKY | មេធាវី Annie DELAHAIE |
| មេធាវី ហុង គីមសួន | មេធាវី Martine JACQUIN | មេធាវី Elizabeth RABESANDRATANA |
| មេធាវី យុង ផានិត | មេធាវី Philippe CANNONE | មេធាវី Karim KHAN |
| មេធាវី គីម ម៉េងឃី | មេធាវី Pierre Olivier SUR | មេធាវី Fabienne TRUSSES-NAPROUS |
| មេធាវី ម៉ុច សុវណ្ណារី | មេធាវី Alain WERNER | មេធាវី Christine MARTINEAU |
| មេធាវី ទី ស្រីនណា | មេធាវី Brianne McGONIGLE | |

F14

# មាតិកា

ទំព័រ


សេចក្តីផ្តើម....................................................................................................៥

I. ចំណុចទី១ : ការភាន់ច្រឡំអំពីយុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូង.............................៧

យុត្តាធិការរូបបុគ្គល........................................................................................៧

(១) ការទទួលខុសត្រូវក្នុងប្រព័ន្ធរដ្ឋបាលដឹកនាំ...................................................១៤

(២) សិទ្ធិអំណាចក្នុងប្រព័ន្ធ Hierarchy............................................................១៥

(៣) របាយការណ៍កោសលវិច័យចិត្តសាស្ត្ររបស់អ្នកជំនាញ........................................១៧

(៤) ការទទួលខុសត្រូវក្នុងរចនាសម្ព័ន្ធគ្រប់គ្រងរបស់បក្សកុម្មុយនីស្តកម្ពុជាប្រជាធិបតេយ្យ..១៨

ក. ពីថ្ងៃទី១៧ មេសា ១៩៧៥ ដល់ថ្ងៃទី៣០ មីនា ១៩៧៦.......................................១៨

ខ. ពីថ្ងៃទី៣០ មីនា ១៩៧៦ ដល់ថ្ងៃទី០៦ មករា ១៩៧៩......................................២០

II. ចំណុចទី២ : ការភាន់ច្រឡំចំពោះការផ្តន្ទាទោស................................................២៦

១. ការភាន់ច្រឡំរបស់ អ.ជ.ស.ដ ក្នុងការសំរេចសេចក្តីដោយមិនបានពិនិត្យមើលវិធាន ៨៧ នៃវិធានផ្ទៃក្នុងរបស់អ.វ.ត.ក..........................................................................................២៦

ក. ភស្តុតាងដោះបន្ទុកដែលមិនទាន់បានបង្ហាញដោយអង្គជំនុំជម្រះ..............................២៩

(១). អំពីបញ្ហាបុគ្គល និងបញ្ហានៃការចាត់តាំង....................................................៣០

(២). អំពីសន្តិសុខ...................................................................................៣១

(៣). ទំនាក់ទំនងភូមិភាគ...........................................................................៣១

(៤). គណៈឃោធាមជ្ឈិម...........................................................................៣១

(៥). គណៈឃោធាមជ្ឈិម...........................................................................៣២

(៦). អគ្គសេនាធិការ.................................................................................៣២

(៧). អគ្គសេនាធិការកងទ័ពបដិវត្តកម្ពុជា........................................................៣៣

(៨). កងពលធំ និងវរសេនាធំឯករាជ្យនៃកងទ័ពបដិវត្តកម្ពុជា...................................៣៤

(៩). ក្រសួងនានា.....................................................................................៣៥

ខ. ប្រភពភស្តុតាងបន្ថែម..........................................................................៣៦

(១) ប្រភពបានមកពី DC-Cam.....................................................................................៣៦

(២) ប្រភពបានមកពីអ្នកជំនាញ Craig C. Etcheson.................................................៣៦

(៣) ប្រភពបានមកពីចម្លើយសារភាពរបស់ជនជាប់ចោទ.........................................៣៧

២.ការភាន់ច្រឡំរបស់ អ.ជ.ស.ដ ក្នុងការសំរេចសេចក្តីដោយផ្តន្ទាទោសជនជាប់ចោទតាមទំនើងចិត្ត៣៨

សេចក្តីសន្និដ្ឋានទូទៅ..........................................................................................................៣៩

សេចក្តីសន្និដ្ឋានចុងក្រោយ...................................................................................................៤២

សំណូមពរ..........................................................................................................................៤៣

00626037



## សេចក្តីផ្តើម

១. ក្រោមកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ(អ.ស.ប) និង រាជរដ្ឋាភិបាលកម្ពុជា សាលាជម្រះក្តី អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) ត្រូវបានបង្កើតឡើងក្នុងគោលបំណងដើម្បីយកមកជំនុំជម្រះ និង ផ្តន្ទាទោសចំពោះជនទាំងឡាយដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម អំពើប្រល័យពូជសាសន៍ និង ការរំលោភបំពានធ្ងន់ធ្ងរ ទៅលើអនុសញ្ញាទីក្រុងស៊ីណែវចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ ។

២. ក្រោមកិច្ចព្រមព្រៀងនេះ ភាគីទាំងពីរមានគោលបំណងរួមគ្នា គឺដើម្បីស្វែងរកយុត្តិធម៌ជូនប្រជាជនកម្ពុជា និង ក៏ដើម្បីធ្វើឲ្យមានការផ្សះផ្សារជាតិ បង្រួបបង្រួមជាតិ និង ទទួលបានសន្តិភាព ព្រមទាំងឲ្យគោរពអធិបតេយ្យភាពជាតិខ្មែរ ។

៣. ក្រោមមាត្រា២ នៃកិច្ចព្រមព្រៀងរវាង អ.ស.ប និង រាជរដ្ឋាភិបាលកម្ពុជា និងមាត្រា១ និងមាត្រា២ (ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក បានផ្តល់សិទ្ធិអំណាចដល់ និងក៏បានដាក់កំហិតនូវយុត្តាធិការលើ អ.វ.ត.ក ផងដែរគឺ ៖

(១).អ.វ.ត.ក មានសិទ្ធិអំណាចជំនុំជម្រះតែទៅលើបទឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ការរំលោភធ្ងន់ធ្ងរលើសអនុសញ្ញាទីក្រុងស៊ីណែវ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ ។

(២). អ.វ.ត.ក មានសិទ្ធិ និង អំណាចជំនុំជម្រះ និង ផ្តន្ទាទោសទៅលើបទឧក្រិដ្ឋកម្ម (១) ដែលបានកើតឡើងក្នុងអំឡុងពេលពីថ្ងៃទី ១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ ។

(៣). អ.វ.ត.ក មានសិទ្ធិអំណាចជំនុំជម្រះ និង ផ្តន្ទាទោសបទឧក្រិដ្ឋកម្ម (១) នៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ។

F14

(៥). អ.វ.ត.ក មានសិទ្ធិអំណាចជំនុំជម្រះ និង ផ្តន្ទាទោសតែទៅលើមេដឹកនាំជាន់ខ្ពស់ កម្ពុជាប្រជាធិបតេយ្យ និង ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម (១) ។

៤. នៅក្នុងដំណាក់កាលជជែកដេញដោលក្នុងអង្គសវនាការសាលាដំបូង មេធាវីការពារជនជាប់ចោទបានលើកឡើងពីភាពគ្មានយុត្តាធិការរបស់ អ.វ.ត.ក ទៅលើជនជាប់ចោទឈ្មោះ **កាំង ហ្កេកអ៊ាវ** ហៅ **ឌុច** ដោយតម្រូវឱ្យតុលាការ អ.វ.ត.ក ពិនិត្យមើលភស្តុតាងបញ្ជាក់ដែលមិនចងភ្ជាប់ឈ្មោះ **កាំង ហ្កេកអ៊ាវ** ហៅ **ឌុច** ទៅនឹងមាត្រា១ និង មាត្រា២(ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ។

៥. ប៉ុន្តែចៅក្រមខកខានមិនបានពិនិត្យ ហើយបន្តសវនាការរហូតដល់ទីបញ្ចប់នៃនីតិវិធី។ ជាលទ្ធផលមេធាវីការពារជនជាប់ចោទបានព្យាយាមលើកឡើងម្តងទៀតនៅក្នុងសេចក្តីសន្និដ្ឋានរបស់ខ្លួនដើម្បីទាមទារឱ្យចៅក្រមពិនិត្យឡើងវិញ ភស្តុតាងដោះបន្ទុកដែលបញ្ជាក់ថាជនជាប់ចោទមិនត្រូវបានចងភ្ជាប់ទៅនឹងមាត្រា១ នៃកិច្ចព្រមព្រៀងរវាង អ.ស.ប និង រាជរដ្ឋាភិបាលកម្ពុជា និង មាត្រា១ និង មាត្រា២(ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ទេ ។

៦. ជាលទ្ធផល ចៅក្រមខកខានជាថ្មីម្តងទៀតក្នុងការពិនិត្យមើលភស្តុតាងដោះបន្ទុកតាមការស្នើសុំរបស់មេធាវីការពារជនជាប់ចោទដដែល ហើយកាលពីថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ អង្គជំនុំជម្រះសាលាដំបូង (អ.ជ.ស.ដ) បានសំរេចប្រកាសចេញសាលក្រមលើសំណុំរឿងលេខ០០១/១៨-០៧-២០០៧/អវតក/អជសដ ផ្តន្ទាទោសឈ្មោះ **កាំង ហ្កេកអ៊ាវ** ហៅ **"ឌុច"** ជាប្រធានស-២១(គុកសំងាត់យោធា) ដែលគ្រប់គ្រងផ្ទាល់ដោយក្រសួងការពារជាតិ និង មន្ទីរអគ្គសេនាធិការកងទ័ពដែលមានឈ្មោះ **សុន សេន** ជាប្រធាន ឱ្យជាប់ពន្ធនាគារសរុបរួមកំណត់ ៣៥ឆ្នាំ ។

៧. យោងសេចក្តីជូនដំណឹងរបស់សហមេធាវីការពារក្តីឱ្យជនជាប់ចោទ **កាំង ហ្កេកអ៊ាវ** ហៅ **"ឌុច"** អំពីបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ របស់អង្គជំនុំជម្រះសាលាដំបូង ("សេចក្តីជូនដំណឹងរបស់សហមេធាវីការពារក្តី")[១]។

---

[១] ឯកសារ E188/8 ។

៨. យោងសំណើរបស់សហមេធាវីការពារក្តីជនជាប់ចោទ **កាំង ហ្កេកអ៊ាវ** ហៅ **"ឌុច"** សុំពន្យាពេលកំណត់សម្រាប់ដាក់សារណា ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១០[២] ។

៩. យោងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល លើសំណើរបស់សហមេធាវីការពារក្តីជនជាប់-ចោទ **កាំង ហ្កេកអ៊ាវ** ហៅ **"ឌុច"** ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០[៣] ។

១០. ដោយហេតុថា សាលក្រមរបស់ អ.ជ.ស.ដ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ បានផ្តន្ទាទោសជនជាប់ចោទដែលមិនស្ថិតនៅក្នុងយុត្តាធិការរបស់ខ្លួន ជាហេតុធ្វើឱ្យសាលក្រមរបស់ អ.ជ.ស.ដ មានកំហុសឆ្គងផ្លូវច្បាប់ ដូចនេះសហមេធាវីការពារក្តីជនជាប់ចោទ **កាំង ហ្កេកអ៊ាវ** ហៅ **"ឌុច"** សូមដាក់ជូននូវសារណាបណ្តឹងសាទុក្ខ ដោយផ្អែកលើទឡ្ហីករណ៍ដូចតទៅ ៖

## I. ទឡ្ហីករណ៍ទី ១: ការគាន់ច្រឡំអំពីយុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូង

## យុត្តាធិការរូបបុគ្គល

១១. យុត្តាធិការលើរូបបុគ្គលត្រូវបានកំណត់ចំពោះមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត ចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរលើច្បាប់ជាតិ និងអន្តរជាតិ។

១២. កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ និងច្បាប់ អ.វ.ត.ក មិនមានចែងច្បាស់អំពី "មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ" និង"ជនទាំងឡាយណា ដែលទទួលខុសត្រូវខ្ពស់បំផុត" នោះទេ។

---

[២] ឯកសារ F6 ។

[៣] ឯកសារ F6/2 ។

១៣. នៅក្នុងកិច្ចព្រមព្រៀង និងច្បាប់ អ.វ.ត.ក <u>ដូចដែលក៏មិនមានចែងដែរថា</u> **កាំង ហ្កេកអ៊ាវ** ហៅ **ឌុច** ជាអ្នកទទួលខុសត្រូវខ្ពស់បំផុត ចំពោះឧក្រិដ្ឋកម្មខាងលើ។

១៤. អង្គជំនុំជម្រះសាលាដំបូង បានសន្មតយក **កាំង ហ្កេកអ៊ាវ** ហៅ **ឌុច** មកឧបកិច្ចឱ្យទៅជាអ្នកទទួលខុសត្រូវខ្ពស់បំផុតសម្រាប់ឱ្យដំណើរការក្តីបានប្រព្រឹត្តទៅជាលក្ខណៈវិជ្ជមាន ដោយពុំបានគិតដល់តម្លៃធម្មនុញ្ញរបស់ជាតិ ដែលត្រូវបានហាមឃាត់នៅក្នុងកថាខណ្ឌ២ ឧបសម្ព័ន្ធ៥ នៃកិច្ចព្រមព្រៀងទីក្រុងប៉ារីសឆ្នាំ១៩៩១ ដែលចែងថា... *"រដ្ឋធម្មនុញ្ញត្រូវហាមឃាត់នូវការអនុវត្តន៍ច្បាប់ឧក្រិដ្ឋទៅលើឧក្រិដ្ឋកម្ម ដែលកើតឡើងក្នុងអតីតកាល "*[៤]។

១៥. មាត្រា៥ នៃច្បាប់ស្តីពីការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យឱ្យនៅក្រៅច្បាប់បានចែងថា *"ច្បាប់នេះអនុគ្រោះទុកពេល ៦ ខែ ក្រោយពីចូលជាធរមាន ឱ្យជនជាសមាជិកអង្គការនយោបាយ ឬជាកម្លាំងយោធានៃក្រុមកម្ពុជាប្រជាធិបតេយ្យ វិលត្រឡប់មករួមរស់ក្រោមការគ្រប់គ្រងរបស់រាជរដ្ឋាភិបាលក្នុងព្រះរាជាណាចក្រកម្ពុជា ដោយមិនយកទោសពៃរ៍ចំពោះបទល្មើសដែលខ្លួនបានប្រព្រឹត្ត"*។ បទដ្ឋានខាងលើគួរតែត្រូវបានយកមកពិនិត្យថ្លឹងថ្លែង ប៉ុន្តែអង្គជំនុំជម្រះសាលាដំបូងបែរជាខកខាន ជាហេតុនាំឱ្យបាត់បង់នូវតម្លៃច្បាប់ជាតិដែលកំពុងនៅជាធរមាន ហើយផ្ទុយនឹងវិធាន ៨៧(១) នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ។

១៦. អង្គជំនុំជម្រះបានយល់ស្របជាមួយការចោទប្រកាន់របស់សហចៅក្រមស៊ើបអង្កេត <u>ដែលស្ថិតក្នុងស្ថានភាពស្រពិចស្រពិលនៅឡើយ</u> ក្នុងការចាត់ទុកជនជាប់ចោទថា ជាអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម ដែលមានចែងក្នុងយុត្តាធិការរបស់ អ.វ.ត.ក។ ក្នុងនោះដោយបានចោទថា ទោះជា **ឌុច** មិនមែនជាមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ <u>**ក៏គាត់អាចត្រូវបានចាត់ទុកថា**</u> ចូលក្នុងប្រភេទនៃអ្នកទទួលខុសត្រូវខ្ពស់បំផុតនៃឧក្រិដ្ឋកម្ម[៥]...។

---

[៤] កិច្ចព្រមព្រៀងស្តីពីដំណោះស្រាយនយោបាយរួមមួយនៃជម្លោះកម្ពុជា ថ្ងៃទី ២៣ តុលា ១៩៩១។

[៥] D99 ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ , កថាខណ្ឌ ១២៩ ។

១៧. ការយល់ស្របទាំងក្នុងស្ថានភាពស្រពិចស្រពិលបែបនេះ គឺជាកំហុសឆ្គងធ្ងន់ធ្ងរបំផុតរបស់អង្គជំនុំជម្រះសាលាដំបូងដោយប្រព្រឹត្តផ្ទុយទៅនឹងវិធាន៨៧(១) នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក និងផ្ទុយទៅនឹងមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា ដែលបានចែងថា "វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ"[៦]។

១៨. ចំណែកឯក្រុមអ្នកជំនាញក៏ស្ទាក់ស្ទើរក្នុងការសន្និដ្ឋានហើយថែមទាំងលើសពីអ្វីដែលច្បាប់ អ.វ.ត.ក បានចែងក្នុងមាត្រា១ ក្នុងការកំណត់អ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរលើច្បាប់ជាតិ និងច្បាប់អន្តរជាតិ ដោយប្រើពាក្យថា... **ករណីនេះហាក់ដូចជាការពិត** ពិសេសចំពោះមេដឹកនាំមួយចំនួននៅថ្នាក់ភូមិភាគ ព្រមទាំងមន្ត្រីនានារបស់មន្ទីរធ្វើទារុណកម្ម និងសួរចម្លើយ ដូចជាទួលស្លែងជាដើម[៧] ។

១៩. យុត្តិសាស្ត្ររបស់តុលាការអន្តរជាតិផ្សេងៗទៀត ដែលបានពិនិត្យផងដែរអំពីអត្ថន័យនៃឃ្លា "មេដឹកនាំជាន់ខ្ពស់បំផុត ដែលត្រូវបានគេសង្ស័យថាជាអ្នកទទួលខុសត្រូវខ្ពស់បំផុត" បានពិចារណាទាំងភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលចោទប្រកាន់ និងកម្រិតនៃការទទួលខុសត្រូវរបស់ជនជាប់ចោទ។ នៅពេលវាយតម្លៃអំពីភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលត្រូវចោទប្រកាន់ ក្រុមប្រឹក្សាកំណត់សមត្ថកិច្ចរឿងក្តីរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី (ICTY) បានផ្អែកលើកត្តានានាដូចជា ចំនួនជនរងគ្រោះ ដែនកំណត់ភូមិសាស្ត្រ និងពេលវេលា របៀបដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្ត ព្រមទាំងចំនួននៃអង្គហេតុនីមួយៗដែលកើតមានឡើង។ ចំណែកឯកម្រិតនៃការទទួលខុសត្រូវរបស់ជនជាប់ចោទ ត្រូវបានវាយតម្លៃដោយផ្អែកលើមូលដ្ឋាននៃការពិចារណានានា ដូចជាកម្រិតនៃការចូលរួមនៅក្នុងឧក្រិដ្ឋកម្មនានា ឋានានុក្រមរបស់ជនជាប់ចោទ រួមបញ្ចូលទាំងអ្នកនៅក្រោមបង្គាប់ និងថ្នាក់លើរបស់គាត់ និងភាពអចិន្ត្រៃយ៍នៃមុខតំណែងរបស់គាត់[៨]។

---

[៦] មាត្រា៣៨ កថាខណ្ឌ៦ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

[៧] សាលក្រមចុះថ្ងៃទី២៦ កក្កដា ២០១០ , កថាខណ្ឌ១៩ ។

[៨] សាលក្រមចុះថ្ងៃទី២៦ កក្កដា ២០១០ , កថាខណ្ឌ២២ ។

២០. ក្នុងការកំណត់អត្តសញ្ញាណមេដឹកនាំជាន់ខ្ពស់បំផុតដែលត្រូវបានសង្ស័យថា ជាអ្នកទទួលខុសត្រូវខ្ពស់បំផុត តុលាការអន្តរជាតិ (ICTY) បានពិចារណាលើកត្តាចម្បងពីរគឺ៖

១ - ការវាយតម្លៃអំពីភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម ដែលជាលក្ខណៈនៃធាតុផ្សំក្នុងច្បាប់ព្រហ្មទណ្ឌ។

២ - ការកម្រិតលើការទទួលខុសត្រូវតាមរយៈឋានានុក្រម ជាលក្ខណៈនៃធាតុផ្សំក្នុងច្បាប់រដ្ឋបាល។

បើផ្អែកតាមយុត្តិសាស្ត្ររបស់តុលាការខាងលើឃើញថា **ឌុច** ដែលពុំត្រូវបានចោទប្រកាន់ជាមេដឹកនាំជាន់ខ្ពស់នោះ គាត់ក៏ពុំត្រូវបានសង្ស័យថា ជាអ្នកទទួលខុសត្រូវខ្ពស់បំផុតដែរ។ ដូច្នេះ តម្រូវឲ្យអង្គជំនុំជម្រះពិនិត្យលើលក្ខខណ្ឌខាងលើសម្រាប់គោលបំណងក្នុងការដោះបន្ទុកដល់ជនជាប់ចោទ។

២១. បើផ្អែកតាមច្បាប់ អ.វ.ត.ក ដែលមានលក្ខណៈរួមបញ្ចូលគ្នានៃបទដ្ឋានព្រហ្មទណ្ឌ និងបទដ្ឋានរដ្ឋបាល សំដៅកាត់ក្តីចោះៗលើមេដឹកនាំជាន់ខ្ពស់ និងអ្នកទទួលខុសត្រូវខ្ពស់បំផុតនៃរបបកម្ពុជាប្រជាធិបតេយ្យ គឺទាមទារឲ្យអង្គជំនុំជម្រះពិចារណាឲ្យស៊ីជម្រៅលើយុត្តាធិការរូបបុគ្គល ដោយផ្អែកលើច្បាប់រដ្ឋបាលរបស់ជាតិជាមូលដ្ឋាន សម្រាប់កំណត់អត្តសញ្ញាណនៃអ្នកទទួលខុសត្រូវខ្ពស់បំផុត។

២២. ករណីដូចជា **ឌុច** គឺមានឯកសារច្បាប់ជាតិបានកំណត់យ៉ាងច្បាស់ណាស់អំពីតួនាទី និងឋានានុក្រមផ្លូវច្បាប់របស់គាត់ដែលពុំមាននៅក្នុងរចនាសម្ព័ន្ធដឹកនាំជាន់ខ្ពស់ និងជាអ្នកទទួលខុសត្រូវខ្ពស់បំផុតនៃឧក្រិដ្ឋកម្មដែលប្រព្រឹត្តក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ[៩]។ ដូចច្នេះ ពុំមានអ្វីគួរឲ្យសង្ស័យទេថា ជនជាប់ចោទត្រូវតែស្ថិតនៅក្រៅយុត្តាធិការរបស់ អ.វ.ត.ក។

២៣. ក្នុងនាមជាប្រធានមន្ទីរស-២១ ដែលជាគុកមួយក្នុងចំណោមគុកជិត ២០០ (ពីររយ) នៅកម្ពុជា នារបបខ្មែរក្រហម[១០]។ មន្ទីរស-២១ មានចំនួនអ្នកទោសដែលបានស្លាប់តិចជាងគុកដទៃទៀតជាច្រើនដង ក្នុងនោះដូចជាគុក **ចុងជ្រោយ** នៅខេត្តកំពង់ឆ្នាំងមានការសម្លាប់អ្នកទោសរហូតដល់ ១៥ ម៉ឺននាក់[១១] និងគុក

---

[៩] ឯកសារ E3/14។

[១០] ឯកសារ E3/220។

[១១] មជ្ឈមណ្ឌលឯកសារកម្ពុជា (គុកខ្មែរក្រហម) ទំព័រ៨១។

00626043



F14

ផ្សេងៗទៀតមានការសម្លាប់ជាច្រើនលើសលុប។ ចំណុចនេះចង់បញ្ជាក់ថា ច្បាប់ អ.វ.ត.ក មិនបានចាត់ទុកជនទាំងឡាយដែលមានឋានៈជាមេគុកចូលក្នុងប្រភេទនៃអ្នកទទួលខុសត្រូវខ្ពស់បំផុត ឡើយ។

២៤. ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែបានចោទប្រកាន់ថា ក្នុងនាមជាអនុលេខាមន្ទីរស-២១ ជនជាប់ចោទបានដឹកនាំក្រុមសួរចម្លើយ និងបានចូលរួមក្នុងការរៀបចំផែនការបង្កើតមន្ទីរស-២១ និងបង្រៀនបុគ្គលិកអំពីបច្ចេកទេសសួរចម្លើយ។ ក្នុងនាមជាប្រធានមន្ទីរស-២១ តួនាទីរបស់គាត់គឺពិនិត្យមើលប្រតិបត្តិការទាំងមូល ដោយរួមបញ្ចូលទាំងការធ្វើចំណារលើចម្លើយសារភាព និងបញ្ជាឲ្យសម្លាប់។ មន្ទីរស-២១ គឺជាមន្ទីរសន្តិសុខសំខាន់បំផុតរបស់កម្ពុជាប្រជាធិបតេយ្យ ដែលត្រូវបានចាត់ទុកជាផ្នែកមួយនៃរចនាសម្ព័ន្ធរបស់បក្សកុម្មុយនីស្តកម្ពុជា ដោយរាយការណ៍ទៅថ្នាក់ដឹកនាំខ្ពស់បំផុតរបស់បក្សកុម្មុយនីស្តកម្ពុជា ធ្វើប្រតិបត្តិការពាសពេញប្រទេស និងទទួលកម្មាភិបាលឋានៈខ្ពស់ និងអ្នកទោសសំខាន់ៗ[១២]។ល។

២៥. ករណីខាងលើនេះ អង្គជំនុំជម្រះបានយល់ស្របដោយមិនត្រឹមត្រូវជាមួយនឹងការសំអាងលេសដែលគ្មានមូលដ្ឋានគតិយុត្តិសមហេតុផលរបស់ដើមចោទ(សហព្រះរាជអាជ្ញា)ក្នុងការដាក់បន្ទុកឲ្យជនជាប់ចោទស្ថិតក្នុងប្រភេទ នៃអ្នកទទួលខុសត្រូវខ្ពស់បំផុត ដោយសំអាងថាមន្ទីរស-២១ គឺជាមន្ទីរសន្តិសុខសំខាន់ ធ្វើប្រតិបត្តិការពាសពេញប្រទេស។ ការសំអាងបែបនេះ ពុំមានលក្ខណៈតក្កៈក្នុងវិស័យច្បាប់សម្រាប់លើកមកបង្ហាញអំពីការធ្វើអត្តសញ្ញាណកម្មនៃអ្នកទទួលខុសត្រូវនោះទេ។ សួរថា **តើច្បាប់តម្រូវឲ្យវិនិច្ឆ័យទោសស្ថាប័នពន្ធនាគារដែលមានវិសាលភាពពាសពេញប្រទេសនោះ ឬមួយក៏វិនិច្ឆ័យទោសបុគ្គលអ្នកទទួលខុសត្រូវខ្ពស់បំផុត ?** ។ តាមទ្រឹស្តីច្បាប់ ការធ្វើអត្តសញ្ញាណកម្មនៃអ្នកទទួលខុសត្រូវខ្ពស់បំផុត គឺផ្អែកលើអំណាចឆន្ទៈរបស់បុគ្គលនោះតាមរយៈឋានានុក្រមដែលកំណត់ក្នុងច្បាប់រដ្ឋបាល។ បញ្ហានៅត្រង់ថា ក្នុងឋានៈជាលេខាមន្ទីរស-២១ **ឌុច** មានតួនាទីត្រឹមតែចាំទទួលអ្នកទោស ដែលបានបញ្ជូនពីគ្រប់ទិសទីមកសួរចម្លើយរួចហើយបញ្ជូនឲ្យកម្ទេចតាមបញ្ជាថ្នាក់លើតែប៉ុណ្ណោះ[១៣]។ ដូចច្នេះ អំពើនេះមិនចាត់ទុកជាលក្ខណៈទទួលខុសត្រូវខ្ពស់បំផុតនោះទេ ព្រោះពុំចេញពីអំណាចឆន្ទៈរបស់ខ្លួនផ្ទាល់ ហើយបានអនុវត្តដូចគ្នានឹងប្រធានមន្ទីរសន្តិសុខផ្សេងៗទៀតនៅទូទាំងប្រទេស ។

[១២] សាលក្រមចុះថ្ងៃទី២៦ កក្កដា ២០១០ , កថាខណ្ឌ២៣ ។

[១៣] D99 ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ,កថាខណ្ឌ៣១។

F14

២៦. ហេតុផលចោទប្រកាន់មួយទៀតដែលខុសឆ្គងជាងនេះ ដោយចោទថា មន្ទីរស-២១ ត្រូវបានចូលរួមបង្កើតឡើងដោយជនជាប់ចោទ[១៤]។ ករណីនេះមិនពិតទេ បើសំអាងលើឋានៈតូចតាច ជាអនុលេខាមន្ទីរស-២១ និងសំអាងលើក្របខណ្ឌនយោបាយដែលមិនមែនជាសមាជិកអចិន្ត្រៃយ៍បក្សនឹងគេ **ជនជាប់ចោទគ្មានសមត្ថភាពផ្លូវអំពើក្នុងការបញ្ចេញមតិ និងផ្តល់ជាគំនិតជូនទៅបក្ស នូវរាល់បញ្ហាដែលទាក់ទងនឹងគោលនយោបាយសន្តិសុខរបស់ជាតិឡើយ ។** ការចោទប្រកាន់បែបនេះពុំតក្កៈទេ។

២៧. ជាការពិត អ្នកច្បាប់ទូទៅតែងតែទទួលស្គាល់ថា ស្ថាប័នពន្ធនាគារ **ជាឧបករណ៍នៃអំណាចរបស់រដ្ឋ** ដូច្នេះរាល់ការបង្កើត ការរំលាយ ឬការផ្លាស់ប្តូរ គឺត្រូវតែស្ថិតក្រោមការសម្រេចរបស់រដ្ឋ ពុំមែនបុគ្គលម្នាក់ ឬពីរនាក់ដែលជាលក្ខណៈរូបវន្ត អាចសម្រេចបង្កើតបានទេ។ ជាក់ស្តែងមន្ទីរស-២១ បានបង្កើតឡើងតាមរយៈសេចក្តីសម្រេចរបស់គណៈកម្មាធិការមជ្ឈិម នាកិច្ចប្រជុំអចិន្ត្រៃយ៍បក្សក្នុងខែតុលា ឆ្នាំ១៩៧៥ ដោយបានប្រគល់សិទ្ធិឲ្យទៅ **សុន សេន** ដែលជាសមាជិកអចិន្ត្រៃយ៍របស់បក្ស និងជាអ្នកទទួលខុសត្រូវលើបញ្ហាសន្តិសុខ[១៥]។

២៨. នៅក្នុងវាក្យខណ្ឌ២ នៃកថាខណ្ឌ៣៣ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលយោងលើកំណត់ហេតុនៃការសួរចម្លើយ បានបង្ហាញក្នុងន័យថា ជនជាប់ចោទក្នុងនាមជាលេខាមន្ទីរស-២១ ក៏ពិតមែន ប៉ុន្តែពុំមានអំណាចផ្លូវច្បាប់ពេញលេញក្នុងការគ្រប់គ្រងលំអិតនោះទេ គឺគាត់មានអំណាចត្រឹមធ្វើការផ្សព្វផ្សាយសេចក្តីសម្រេចពីថ្នាក់លើតែប៉ុណ្ណោះ[១៦]។

---

[១៤] សាលក្រមថ្ងៃទី២៦ កក្កដា ២០១០ , កថាខណ្ឌ២៣ ។

[១៥] ឯកសារស្វែងរកការពិតរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា លេខ២ ខែកុម្ភៈ ឆ្នាំ២000 ទំព័រ៥៣ (ខ្មែរ)។

[១៦] D99 ដីកាបញ្ជូនរឿងទៅជំនុំជម្រះ,កថាខណ្ឌ៣៣ និង E3/26 កំណត់ហេតុនៃការសួរចម្លើយថ្ងៃទី០២ ខែតុលា ឆ្នាំ២០០៧ ទំព័រ៣(ខ្មែរ)។

២៩. ដូចមានបញ្ជាក់ស្រាប់នៅក្នុងកថាខណ្ឌ៤៩ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា... "មន្ទីរ ស-២១ ដែលត្រូវបានស្គាល់ថាជាទួលស្លែងនោះ បានប្រតិបត្តិការតាមការណែនាំ និងក្រោមបញ្ជាផ្ទាល់របស់អាជ្ញាធរខ្ពស់បំផុតនៃបក្សកុម្មុយនីស្តកម្ពុជាប្រជាធិបតេយ្យ"[១៧]។

៣០. តាមទស្សនៈរបស់មេធាវីក្រុម CARTWRIGHT ក៏បានយល់ឃើញដែរថា បក្សកុម្មុយនីស្តកម្ពុជា ជាអ្នកកំណត់អត្តសញ្ញាណ"ខ្មាំង" និងជាញឹកញាប់ជាអ្នកបញ្ជាឲ្យធ្វើការចាប់ខ្លួន។ គាត់បានបញ្ជាក់បន្ថែមទៀតថា ជនជាប់ចោទមិនបានដឹងអំពីសេចក្តីសម្រេចសម្លាប់បំផុតចុះថ្ងៃទី៣០ ខែមិនា ឆ្នាំ ១៩៧៦ នោះទេ ដូច្នេះហើយមិនអាចនិយាយបានថា គាត់បានចូលរួមចំណែករៀបចំគោលនយោបាយទាំងនេះ នោះទេ[១៨]...។ ហេតុផលច្បាស់លាស់ទាំងនេះ បញ្ជាក់ថា **ឌុច** ពុំមែនជាអ្នកទទួលខុសត្រូវខ្ពស់បំផុត ចំពោះឧក្រិដ្ឋកម្មខាងលើនេះទេ។

៣១. មានភស្តុតាងជាច្រើនទៀតដែលបញ្ជាក់ថា **ឌុច** គ្មានសិទ្ធិអំណាចក្នុងការសម្រេចឲ្យចាប់ ឬបញ្ជាឲ្យសម្លាប់អ្នកទោសទេ។ ករណីដូចជាការស្លាប់របស់ **កុយ ធួន, វ៉ាយ គីមហួរ, វន វ៉េត, ណាត** គឺស្ថិតក្រោមការសម្រេចឲ្យចាប់ខ្លួន និងឲ្យកំទេចពីថ្នាក់លើទាំងអស់ ពិសេសក្រោមបញ្ជារបស់ **សុន សេន**[១៩]និងអ្នកទោសជាច្រើននាក់ទៀតដូចជា៖សាស្ត្រាចារ្យ **ភឹង ឌុន**, ពេទ្យ**វ័ត្ត គត់** និងមិត្តភ័ក្តមួយចំនួនធំ ព្រមទាំងប្អូនថ្លៃរបស់ខ្លួនផ្ទាល់ក៏ **ឌុច** ពុំមានសិទ្ធិអន្តរាគមន៍ ឬសម្រេចអ្វីទាំងអស់[២០]។ លក្ខណៈទាំងនេះហើយដែលបញ្ជាក់ថា **ឌុច** ពុំមែនជាអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរលើច្បាប់ជាតិ និងអន្តរជាតិ។

[១៧] D3 ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ, កថាខណ្ឌ៤៩ ។

[១៨] សាលក្រមចុះថ្ងៃទី២៦ កក្កដា ២០១០, កថាខណ្ឌ ៣៩៩ ។

[១៩] ឯកសារ E3/17 កំណត់ហេតុសួរចម្លើយ ឌុច របស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០៧ ទំព័រទី៥(ខ្មែរ)។

[២០] ឯកសារ E3/929 កំណត់ហេតុសួរចម្លើយ ឌុច របស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី៣១ ខែមិនា ឆ្នាំ២០០៨ ទំព័រទី៣-៤ (ខ្មែរ)។

៣២. នៅក្នុងកថាខណ្ឌ ២៥៦ នៃសាលក្រមចុះថ្ងៃទី២៦ កក្កដា ២០១០ អង្គជំនុំជម្រះសាលាដំបូងបានទទួលស្គាល់ថា ជនជាប់ចោទបានបំពេញតួនាទីរបស់ខ្លួនតាមបញ្ជារបស់គណៈកម្មាធិការអចិន្ត្រៃយ៍ ហើយបានដឹកនាំបញ្ជាទៅបុគ្គលិករបស់ខ្លួនបន្តទៀត។ ដោយពិចារណាអំពីតួនាទីរបស់បុគ្គលិកទាំងអស់នោះ នៅក្នុងរដ្ឋមួយដែលមានការគ្រប់គ្រង អង្គជំនុំជម្រះបានសន្និដ្ឋានថា អ្នកសួរចម្លើយនៅមន្ទីរស-២១ និងមន្ទីរស-២៤ ដែលបានប្រព្រឹត្តអំពើទារុណកម្មទាំងឡាយ បានអនុវត្តសមត្ថកិច្ចជាផ្លូវការរបស់ខ្លួន។ អំពើទាំងនេះត្រូវបានចាត់ទុកជា *សមត្ថកិច្ចផ្លូវការរបស់ចារី* ។ លក្ខខណ្ឌខាងលើនេះ អង្គជំនុំជម្រះគួរតែពិចារណាចំពោះ **ឌុច** ផងដែរ ព្រោះជាទំរង់តែមួយនៃការអនុវត្តន៍តាមបញ្ជា។

៣៣. បើពិចារណាទៅលើប្រព័ន្ធរដ្ឋបាលដឹកនាំតាមបែប **Hierarchy** ការទទួលខុសត្រូវរបស់បុគ្គលម្នាក់ៗ គឺផ្អែកលើអំណាចឋានានុក្រមរបស់បុគ្គលនោះ ដែលត្រូវបានកំណត់ដោយច្បាប់។ បានសេចក្តីថា **បើបុគ្គលនោះ មានឋានានុក្រមខ្ពស់ គឺមានអំណាចខ្ពស់ក្នុងការចេញបញ្ជា និងសម្រេចឱ្យអនុវត្តបញ្ជា ហើយក៏មានការទទួលខុសត្រូវខ្ពស់ចំពោះសេចក្តីសម្រេចរបស់ខ្លួន**។ ករណីចំពោះ **ឌុច** គាត់មានឋានៈ ជាលេខាមន្ទីរស-២១ ហើយក៏មិនមែនជាសមាជិកអចិន្ត្រៃយ៍ក្នុងបក្សកុម្មុយនីស្តកម្ពុជាប្រជាធិបតេយ្យ គាត់គ្មានសិទ្ធិអំណាចក្នុងការសម្រេចឱ្យចាប់ និងបញ្ជាឱ្យសម្លាប់បុគ្គលណាទាំងអស់ គឺតាមតែថ្នាក់លើបញ្ជា[២១]។ ដូច្នេះតើគួរឱ្យ **ឌុច** ជាអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មខាងលើនេះយ៉ាងដូចម្តេច?។

### *(១) ការទទួលខុសត្រូវក្នុងប្រព័ន្ធរដ្ឋបាលដឹកនាំ*

**បើជាមេដឹកនាំជាន់ខ្ពស់, បុគ្គលមានឋានានុក្រមខ្ពស់ => មានសិទ្ធិបញ្ជា និង មានសិទ្ធិសម្រេចខ្ពស់ => មានការទទួលខុសត្រូវខ្ពស់ ។**

**ឌុច មិនមែនជាមេដឹកនាំជាន់ខ្ពស់, មានឋានានុក្រមទាប => គ្មានសិទ្ធិបញ្ជា និង គ្មានសិទ្ធិសម្រេច => មានការទទួលខុសត្រូវទាប។**

---

[២១] D99 ដីកាបញ្ជូនរឿងទៅជំនុំជម្រះ, កថាខណ្ឌ១១៨ ។

F14

## (២) *សិទ្ធិអំណាចក្នុងប្រព័ន្ធ Hierarchy*

- **ស្ថាប័នព្រះមហាក្សត្រ និង នីតិបញ្ញត្តិ** ៖ *ច្បាប់*

- **ស្ថាប័ននីតិប្រតិបត្តិ** ៖




៣៨. នៅក្នុងកថាខណ្ឌ ២៩ នៃសាលក្រមចុះថ្ងៃទី២៦ កក្កដា ឆ្នាំ២០១០ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា ក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ គឺជាច្បាប់ជាតិជាធរមានដែលគ្របដណ្តប់នៅក្នុងអំឡុងឆ្នាំ១៩៧៥ ដល់ឆ្នាំ ១៩៧៩...។

៣៩. មាត្រា៩៩ ក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ដដែលបានចែងថា "*មិនទុកជាអំពើល្មើសក្នុងបទព្រហ្មទណ្ឌ ទេ កាលណាបើ អំពើទាំងឡាយ នោះ ធ្វើតាមបង្គាប់ របស់ច្បាប់, ហើយអ្នកបញ្ជាឲ្យធ្វើ ក៏ជាអាជ្ញាធរ ធម្មានុរូប ដែរ*"[២២]។

[២២] ឯកសារ D99/3/3, ERN 00222205 (ខ្មែរ) ។

00626048



F14

៣៦. តាមច្បាប់ទំនៀមទំលាប់ខ្មែរពីមុនៗក៏មានចែងអំពីករណីសម្រាល ឬរួចផុតពីការទទួលខុសត្រូវ ចំពោះជនដែលបានប្រព្រឹត្តអំពើល្មើសតាមការបញ្ជាពីថ្នាក់លើ ឬបុគ្គលណាមួយ។ ដូចជានៅក្នុងការកាត់សេចក្តីរបស់ព្រះរាជា ឲ្យបុរសម្នាក់ដែលធ្វើតាមបញ្ជាគេរួចផុតពីការទទួលខុសត្រូវចំពោះអំពើរបស់ខ្លួន[២៣]...។

៣៧. ច្បាប់ អ.វ.ត.ក ដែលមានមូលដ្ឋានចេញពីក្រមព្រហ្មទណ្ឌ ឆ្នាំ១៩៥៦ ក៏ដូចគ្នាដែរគឺ មិនអនុញ្ញាតឲ្យផ្តន្ទាទោសជនដែលទទួលខុសត្រូវទាប ចំពោះឧក្រិដ្ឋកម្មដែលប្រព្រឹត្តក្នុងរបបកម្ពុជាប្រជាធិបតេយ្យទេ ព្រោះដោយយល់ថា ជនទាំងនោះអនុវត្តតាមបញ្ជារបស់ថ្នាក់លើ។

៣៨. ក្នុងន័យនេះ សហព្រះរាជអាជ្ញា ក៏ដូចជាអង្គជំនុំជម្រះទាំងមូល បានយល់ដឹងដោយស្ងៀមស្ងាត់នូវខ្លឹមសារនៃបទដ្ឋានច្បាប់ខាងលើ។ លើសពីនេះព្រមទាំងទទួលស្គាល់ ដូចមានបញ្ជាក់ស្រាប់នៅក្នុងកថាខណ្ឌ ៤៩ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា និងក្នុងកថាខណ្ឌ២៥៦ នៃសាលក្រម ចុះថ្ងៃទី២៦ កក្កដា ឆ្នាំ២០១០ ថាជនជាប់ចោទបានបំពេញតួនាទីរបស់ខ្លួនតាមបញ្ជារបស់គណៈកម្មាធិការអចិន្ត្រៃយ៍។ **ចុះហេតុដូចម្តេចបានជាទាំងសហព្រះរាជអាជ្ញា ទាំងអង្គជំនុំជម្រះ ប្រឹងទាញ ឌុច ឲ្យចូលក្នុងយុត្តាធិការរបស់ អ.វ.ត.ក ដោយមិនពិចារណាទៅលើបទដ្ឋាននៃច្បាប់ខាងលើនេះ ?** ការទាញទាំងកំរោលបែបនេះបានបំពានទៅលើច្បាប់ជាតិ ដែលសហព្រះរាជអាជ្ញា ក៏ដូចជា អង្គជំនុំជម្រះសាលាដំបូងទទួលស្គាល់ជាធរមាន(ក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦) និងបានរំលោភលើមាត្រា ១៥(១) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ(ICCPR) ។

៣៩. នៅក្នុងករណីដដែលនេះដែរ ជាក់ស្តែងណាស់ពុំឃើញមានការចោទប្រកាន់ណាមួយផ្សេងទៀតទៅលើជនដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មតាមបញ្ជារបស់ថ្នាក់លើ ឬអង្គការ ដូចជាប្រធានមន្ទីរសន្តិសុខដទៃទៀត និងបុគ្គលផ្សេងៗទៀត ។ល។ លក្ខខណ្ឌតែមួយនេះ **ឌុច** ត្រូវតែទទួលបានសិទ្ធិជាស្វ័យប្រវត្តិតាមផ្លូវច្បាប់ដូចពួកគេដែរ ពិសេសសិទ្ធិដែលមានចែងក្នុងមាត្រា ៣១(២) នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣។

---

[២៣] ប្រជុំរឿងព្រេងខ្មែរ ភាគ ៣ ទំព័រ ១៣៧-១៤៤ ។

## (៣) របាយការណ៍កោសលវិច័យចិត្តសាស្ត្ររបស់អ្នកជំនាញ

៤០. មានហេតុផលផ្សេងទៀតកាន់តែច្បាស់ជាងនេះថា **កាំង ហ្គេកអ៊ាវ** ហៅ **ឌុច** មិនមែនជាអ្នកទទួលខុសត្រូវខ្ពស់បំផុតទេ ព្រោះបើតាមរបាយការណ៍កោសលវិច័យចិត្តសាស្ត្ររបស់អ្នកជំនាញបានបង្ហាញពីភាពមិនរឹងមាំនៃកាយសម្បទារបស់គាត់ទាំងកំលាំងបញ្ញា និងស្មារតី។ ក្នុងរបាយការណ៍បានញ្ជាក់ថា "ចាប់តាំងពីអំឡុងពេលនៃការជាប់ឃុំឃាំងចន្លោះពីឆ្នាំ ១៩៦៨-១៩៧០ **ឌុច** តែងតែមានការភ័យខ្លាចស្លាប់ជានិច្ច។ ការភ័យខ្លាចនោះមានជាប្រចាំរាល់ថ្ងៃ ពីព្រោះគាត់បានឃើញជនជាប់ឃុំត្រូវគេកាត់ទោសប្រហារជីវិត។ **ឌុច** មិនបានទទួលរងទារុណកម្មទេ ប៉ុន្តែការភ័យខ្លាចការស្លាប់ ភាពមិនទៀងទាត់ជាអចិន្ត្រៃយ៍នៃហេតុការណ៍ ដែលអាចកើតឡើងមានអានុភាពឲ្យ **ឌុច** ***ស្លុត***"[២៤]។ លក្ខណៈនេះ បញ្ជាក់ថា **ឌុច** ជាបុគ្គលដែលមានស្មារតីទន់ខ្សោយ។

៤១. ក្នុងឆ្នាំ ១៩៧៨ ការភ័យខ្លាចបានសម្តែងចេញតាមរយៈទិដ្ឋភាពធ្លាក់ចុះទាំងកម្លាំងកាយទាំងកម្លាំងចិត្ត។ របាយការណ៍បានដកស្រង់សំដី **ឌុច** និយាយថា *"...ខ្ញុំមានការរន្ធត់ តក់ស្លុតជាយូរមកហើយ នៅពេលឃើញការចាប់ខ្លួន ប្រព្រឹត្តទៅមិនធម្មតា..."*[២៥]។

៤២. ការធ្វើសន្និដ្ឋានរបស់អ្នកជំនាញបង្កប់នូវភាពអល់ឯកថា "**ឌុច** មិនមានរោគវិកលចរិត មិនមានរោគចិត្ត មិនមានរោគខាងផ្នែកចិត្តសាស្ត្រ និងមិនមានរោគវិបត្តិផ្លូវចិត្តទេ **ប៉ុន្តែអាចមានការជះផលលើ វិបត្តិផ្លូវចិត្ត...**"[២៦]។ លក្ខខណ្ឌទាំងនេះតាមគោលការណ៍ "វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ"[២៧] **ឌុច** ត្រូវបានចាត់ទុកថាជាជនមានវិបត្តិផ្លូវចិត្តដែលជាប្រភេទមួយនៃជំងឺចិត្តសាស្ត្រ។ ហេតុដូចនេះ កាន់តែពុំមានធាតុគ្រប់គ្រាន់តាមផ្លូវច្បាប់សម្រាប់ទាញឲ្យ **ឌុច** ក្លាយជាអ្នកទទួលខុសត្រូវខ្ពស់បំផុតកើតឡើយ។

---

[២៤] ឯកសារ E3/509 ទំព័រ៣៦ (ខ្មែរ)។

[២៥] ឯកសារ E3/509 ទំព័រ៤១ (ខ្មែរ)។

[២៦] ឯកសារ E3/509 ទំព័រ១០៦។

[២៧] មាត្រា៣៨ កថាខណ្ឌ ៦ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា ។

F14

## (៥) ការទទួលខុសត្រូវក្នុងរចនាសម្ព័ន្ធគ្រប់គ្រងរបស់បក្សកុម្មុយនីស្តកម្ពុជាប្រជាធិបតេយ្យ៖

៤៣. បើពិនិត្យមើលរចនាសម្ព័ន្ធគ្រប់គ្រងរបស់បក្សកុម្មុយនីស្តកម្ពុជាប្រជាធិបតេយ្យ គេអាចកំណត់អ្នកដែលទទួលខុសត្រូវខ្ពស់បំផុតទៅតាមដំណាក់កាលពីរផ្សេងៗគ្នាគឺ ៖

### ក. ពីថ្ងៃទី១៧ មេសា ១៩៧៥ ដល់ថ្ងៃទី៣០ មិនា ១៩៧៦

៤៤. នៅថ្ងៃទី១៧ មេសា ១៩៧៥ ពេលកងទ័ពខ្មែរក្រហមចូលដល់ក្រុងភ្នំពេញភ្លាមឧក្រិដ្ឋកម្មក៏ចាប់កើតមានដោយចំហ និងសម្ងាត់ (ការជំលៀសប្រជាជនដោយប្រើកម្លាំងយោធាជាចំហ និងការលួចសម្លាប់ស្ងាត់ៗ) ក្នុងទិសដៅច្បាស់លាស់តាមផែនការដែលបានគ្រោងទុក គឺធ្វើឱ្យប្រជាជនកម្ពុជាទាំងមូលក្លាយជាទាសករ ដូចដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី១៨ កក្កដា ២០០៨ ត្រង់កថាខណ្ឌទី១៥ និងទី១៦[២៨] ហើយស្របគ្នាទៅនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ ២០០៨ ត្រង់កថាខណ្ឌទី១០ និងទី១១[២៩] ដែលបានកំណត់ច្បាស់ថា "បក្សកុម្មុយនីស្តកម្ពុជា ជាអ្នកបញ្ជា" ។

៤៥. ត្រង់កថាខណ្ឌទី១២ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី០៨ សីហា ២០០៨ បានលាតត្រដាងបង្ហាញយ៉ាងច្បាស់ថា "ការកាប់សម្លាប់ក្រៅច្បាប់ដែលមានលក្ខណៈនយោបាយនេះប្រតិបត្តិឡើងជាដំបូងដោយអង្គភាពយោធា"[៣០] ។

៤៦. មុន និងក្រោយថ្ងៃ១៧ មេសា ១៩៧៥ បន្តិច អង្គភាពយោធាគ្រប់កងពល និងរដ្ឋអំណាចមូលដ្ឋានគ្រប់ភូមិភាគ ស្ថិតនៅក្រោមបញ្ជារបស់លេខា និងអនុលេខាភូមិភាគ។

៤៧. ភូមិភាគដែលរួមគ្នាវាយយកភ្នំពេញមាន៖

---

[២៨] D96 ដីកាសន្និដ្ឋានស្ថាពរ ទំព័រ១១ , ERN 00205833 (ខ្មែរ)។

[២៩] D99 ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ចុះថ្ងៃទី០៨ សីហា ឆ្នាំ២០០៨ ទំព័រ៦, ERN 00212149 (ខ្មែរ)។

[៣០] D99 ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ចុះថ្ងៃទី០៨ សីហា ឆ្នាំ២០០៨ ទំព័រ៦-៧ , ENR 00212149-00212150 (ខ្មែរ)។

F14

១. ភូមិភាគបូព៌ា មានឈ្មោះ **សោ យ៉ាន់** ហៅ **ភឹម** ជាលេខា

២. ភូមិភាគពិសេស មានឈ្មោះ **វន វ៉េត** និង **សុន សេន**

៣. ភូមិភាគនិរតីចាស់ មានឈ្មោះ **អ៊ឹង ជឿន** ហៅ **ម៉ុក** និង **ជូ ជេត** ហៅ **ស៊ី**

៤. ភូមិភាគឧត្តរចាស់ មានឈ្មោះ **កុយ ធួន** និង **កែ ពក**។

៤៨. ចំណែក **រស់ ញឹម** លេខាភូមិភាគពាយ័ព្យ វាយផ្តាច់មុខយកបាត់ដំបង។

៤៩. ដូចនេះ សរុបរួមទាំងវាយយកភ្នំពេញ និងបាត់ដំបង មានចំនួន ១០ នាក់គឺ:

១. **ប៉ុល ពត**

២. **នួន ជា**

៣. **សោ យ៉ាន់** ហៅ **ភឹម**

៤. **អ៊ឹង ជឿន** ហៅ **ម៉ុក**

៥. **វន វ៉េត**

៦. **សុន សេន**

៧. **កុយ ធួន**

៨. **រស់ ញឹម**

៩. **ជូ ជេត** ហៅ **ស៊ី**

១០. **កែ ពក**

៥០. ជនទាំងនេះ បន្ទាប់ពីដណ្តើមរដ្ឋអំណាចបានហើយ ក៏ចាប់ផ្តើមអនុវត្តផែនការឧក្រិដ្ឋរបស់ខ្លួនភ្លាម ។ ដូចនេះគួរតែត្រូវបានចាត់ទុកថា "ជាអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ជាតិ និងច្បាប់អន្តរជាតិ" ចាប់ពីថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ រហូតដល់ ថ្ងៃទី៣០ មិនា ១៩៧៦ ។

៥១. ចំពោះ **កាំង ហ្កេកអ៊ាវ** ហៅ **ឌុច** មិនមែនជាជនទាំងឡាយ ដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះ ឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ជាតិ និងច្បាប់អន្តរជាតិនោះទេ ព្រោះថា:

**ទី១.** ពីថ្ងៃទី១៧ មេសា ១៩៧៥ និងក្រោយបន្តិចមក អ្នកជំលៀសប្រជាជន សម្លាប់ប្រជាជន គឺដោយអង្គភាពយោធា "កថាខណ្ឌទី១២ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ" **ឌុច** ជានគរបាល គាត់មិន មែនជាយោធាទេ។

**ទី២.** ពេលជម្លៀសប្រជាជនពីភ្នំពេញទៅជនបទ ដែលមានការសម្លាប់បណ្តើរៗពេលនោះ **ឌុច** នៅឈរជើងឯអមលាំងស្រុកថ្ពង ខេត្តកំពង់ស្ពឺ។ ដូច្នេះ **ឌុច** មិនបានចូលរួមជម្លៀសប្រជាជនចេញពីភ្នំពេញទេ ។

**ទី៣.** ឈ្មោះលេខាភូមិភាគ ដែលទទួលខុសត្រូវក្នុងការវាយយកភ្នំពេញ និងបាត់ដំបង បានជម្លៀសប្រជាជន កាប់សម្លាប់ប្រជាជនមានឈ្មោះ ១០នាក់ ដោយមិនមានឈ្មោះ **ឌុច** ទេ។

## ខ. ពីថ្ងៃទី៣០ មិនា ១៩៧៦ ដល់ថ្ងៃទី០៦ មករា ១៩៧៩

៥២. កថាខណ្ឌទី៣៥ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ចុះថ្ងៃទី ០៨ សីហា ២០០៨ របស់សហចៅក្រមស៊ើបអង្កេតដែលបានទទួលស្គាល់ថា "បក្សបានបញ្ជាក់អំពីក្របខណ្ឌដែលមានសិទ្ធិអំណាចសម្រេចកម្ទេច..." **តើជនណាខ្លះដែលមានសិទ្ធិអំណាចសម្រេចកម្ទេច** ? អ្នកដែលមានសិទ្ធិអំណាចសម្រេចកម្ទេច គឺអ្នកទាំងនោះហើយ ដែលជាជនទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភច្បាប់ ។

៥៣. យោងតាមសេចក្តីសម្រេចរបស់គណៈមជ្ឈិមចុះថ្ងៃទី៣០ មិនា ១៩៧៦[៣១] បានសម្រេចប្រគល់សិទ្ធិឲ្យមនុស្ស៤ក្រុម មានសិទ្ធិសម្រេចកម្ទេចក្នុងជួរ និងក្រៅជួរ គឺ:

- បើនៅក្នុងក្របខណ្ឌមូលដ្ឋាន ត្រូវអចិន្ត្រៃយ៍ភូមិភាគសម្រេច
- ជុំវិញមន្ទីរមជ្ឈិម ត្រូវគណៈមន្ទីរមជ្ឈិមសម្រេច
- តំបន់ឯករាជ្យ ត្រូវអចិន្ត្រៃយ៍សម្រេច

[៣១] សេចក្តីសំរេចមជ្ឈិម ចុះថ្ងៃទី៣០ មីនា ១៩៧៦ , ERN 00003136-00003142 (ខ្មែរ)។

- កងទ័ពមជ្ឈិម ត្រូវសេនាធិការសម្រេច ។

៥៤. ដូច្នេះ មនុស្ស៤ក្រុមនេះហើយដែលអាចចាត់ទុកថា គឺជាជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ជាតិ និងអន្តរជាតិ។

៥៥. ចំណែកឯ **ឌុច** គឺជាជនដែលស្ថិតក្នុងចំណោមអ្នកទទួលខុសត្រូវ **ទាប** ចំពោះឧក្រិដ្ឋកម្ម និង ការរំលោភយ៉ាងធ្ងន់ធ្ងរលើច្បាប់ជាតិ និងអន្តរជាតិ[៣២] ហើយដែលច្បាប់ អ.វ.ត.ក មិនតម្រូវឱ្យផ្តន្ទាទោសទេ ។

៥៦. អង្គជំនុំជម្រះសាលាដំបូង នៃ អ.វ.ត.ក បានប្រើប្រាស់ប្រព័ន្ធពង្រីកសិទ្ធិអំណាចរបស់ខ្លួនអោយចេញផុតពីយុត្តាធិការរបស់ខ្លួនពីមាត្រា១ នៃកិច្ចព្រមព្រៀងរវាង អ.ស.ប និង រាជរដ្ឋាភិបាលកម្ពុជា និងមាត្រា១ និងមាត្រា២(ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ក្នុងការជំនុំជម្រះ **កាំង ហ្កេកអ៊ាវ** ហៅ **ឌុច**[៣៣] ។

៥៧. សាលាដំបូង អ.វ.ត.ក មិនបានពិនិត្យច្បាស់លាស់ទៅលើយុត្តាធិការបុគ្គលដូចមានចែងក្នុងមាត្រា១ នៃកិច្ចព្រមព្រៀងរវាង អ.ស.ប និងរាជរដ្ឋាភិបាលកម្ពុជា និងមាត្រា១ និងមាត្រា២(ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក[៣៤] ហើយធ្វើផ្ទុយនឹងទំនៀមទំលាប់អន្តរជាតិដូចការផ្តាប់អនុវត្តនៅ Nuremberg និង Tokyo ។ នៅ Nuremberg និង Tokyo អង្គជំនុំជម្រះមិនបានធ្វើការចោទប្រកាន់ ឬជំនុំជម្រះដល់បុគ្គលទាំងឡាយណាដែលជាទាហានសម្ព័ន្ធមិត្តនោះទេ[៣៥] ទោះបីជាគេបានដឹងឮជាទូទៅថា ក្រុមទាហានសម្ព័ន្ធមិត្តបានប្រព្រឹត្តឧក្រិដ្ឋកម្មដូចគ្នានឹងពួកបក្សសម្ព័ន្ធយោធានៅអឺរ៉ុបនិងឧក្រិដ្ឋជនសង្គ្រាមនៅអាស៊ីបូព៌ាយ៉ាងណាក៏-ដោយ ក៏ព្រោះតែយុត្តាធិការសាលាជម្រះក្តីបានដាក់កំហិតទៅលើសិទ្ធិអំណាចរបស់អង្គជំនុំជម្រះត្រឹមតែលើពួកបក្សសម្ព័ន្ធយោធានៅអឺរ៉ុប និង ឧក្រិដ្ឋជនសង្គ្រាមនៅអាស៊ីបូព៌ាតែប៉ុណ្ណោះហើយថាគ្មានអ្នកទទួល

---

[៣២] E3/32 របាយការណ៍ Craig C. Etcheson, ទំព័រ៧ ERN 00314784 និងទំព័រ១៨ ERN 00314795 (ខ្មែរ) ។

[៣៣] សាលក្រមចុះថ្ងៃទី២៦ កក្កដា ២០១០, កថាខណ្ឌ១៩ ។

[៣៤] សាលក្រមចុះថ្ងៃទី២៦ កក្កដា ២០១០, កថាខណ្ឌ១៨ ។

[៣៥] មាត្រា៦ នៃច្បាប់ស្តីពីលក្ខន្តិកៈតុលាការអន្តរជាតិ Nuremberg និង មាត្រា៥ នៃធម្មនុញ្ញសាលាជម្រះក្តីយោធាអន្តរជាតិសម្រាប់អាស៊ីបូព៌ា (Tokyo) ។

ខុសត្រូវសាខាបក្សណាស៊ីថ្នាក់មូលដ្ឋានណាម្នាក់ត្រូវបានអង្គជំនុំជម្រះចោទប្រកាន់ ឬធ្វើការជំនុំជម្រះនោះទេ គឺមានតែមេដឹកនាំបក្សណាស៊ី និងអ្នកទទួលខុសត្រូវជាន់ខ្ពស់នៃបណ្តាពួកឧត្តមសេនីយ៍យោធារបស់បក្សសម្ព័ន្ធយោធានៅអឺរ៉ុបប៉ុណ្ណោះ ដែលរងការចោទប្រកាន់និងផ្តន្ទាទោស ។

៥៨. អង្គជំនុំជម្រះក៏មិនធ្លាប់ ឬ មិនអនុញ្ញាតអោយប្រើប្រាស់ប្រព័ន្ធស្វ័យពង្រីកអំណាច ដើម្បីពង្រីកនូវសិទ្ធិអំណាចរបស់ខ្លួន ដើម្បីធ្វើការចោទប្រកាន់ទៅលើក្រុមទាហានសម្ព័ន្ធមិត្តដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មដូចគ្នានឹងពួកបក្សសម្ព័ន្ធយោធានៅអឺរ៉ុប និង ឧក្រិដ្ឋជនសង្គ្រាមនៅអាស៊ីបូព៌ា បើទោះជាគេប្រមើលឃើញថាបទឧក្រិដ្ឋបង្កើតដោយពួកសម្ព័ន្ធមិត្តមានកំរិតធ្ងន់ធ្ងរដូចគ្នាឬ ធ្ងន់ជាងក៏ដោយ។ វាមានន័យថាអង្គជំនុំជម្រះត្រូវតែគោរពតាមច្បាប់ដែលកំណត់នូវសិទ្ធិ និងអំណាចរបស់ខ្លួនដែលមានត្រឹមតែច្បាប់កំណត់តែប៉ុណ្ណោះ បើទោះបីជាអង្គជំនុំជម្រះយល់ឃើញថាអ្នកផ្សេងទៀតបានប្រព្រឹត្តឧក្រិដ្ឋកម្មធ្ងន់ធ្ងរដូចតែគ្នាក៏ដោយ នោះគឺមានន័យថា **ច្បាប់គឺរឹងត្អឹង ប៉ុន្តែវាជាច្បាប់** Dura Lex, Sed Lex (Law is hard ,but is law) ។

៥៩. សាលាដំបូង អ.វ.ត.ក ប្រើប្រាស់ទំនៀមទំលាប់អន្តរជាតិដោយប្រមើលមើលសេចក្តីសម្រេចរបស់ ICTY និង ICTR ដែលកំហិតយុត្តាធិការទៅលើតែបទឧក្រិដ្ឋមិនដាក់កំហិតទៅលើឋានៈបុគ្គល[៣៦] ដូចនៅ Nuremberg, Tokyo និង ECCC ទេ។ ការប្រៀបធៀបបែបនេះ គឺជាកំហុសឆ្គងក្នុងការប្រើប្រាស់ប្រភពច្បាប់អន្តរជាតិ ដែលកើតពីទំនៀមទំលាប់អន្តរជាតិដោយហេតុថាប្រភពច្បាប់ដែលយកមកប្រើប្រាស់និងបុព្វហេតុកកើតបទល្មើសគឺមិនដូចគ្នាទាំងស្រុង ដែលអាចអោយគេយកមកបង្កើតបានជា ករណីគំរូបានទេ (មិនអាចក្លាយជាករណីយុត្តិសាស្ត្រ) ។

[៣៦] មាត្រា៦ នៃលក្ខន្តិកៈតុលាការអន្តរជាតិប្រទេស រ្វាន់ដា ១៩៩៤ (ICTR) និង មាត្រា៦ នៃលក្ខន្តិកៈតុលាការអន្តរជាតិប្រទេសយូហ្គោស្លាវី ១៩៩៤ (ICTY)។

៦០. តាមពិតទៅ អ.វ.ត.ក មានច្បាប់កំណត់យុត្តាធិការគ្រប់គ្រាន់[៣៧] ដោយមិនចាំបាច់ទាមទារអោយអង្គជំនុំជម្រះព្យាយាមប្រើប្រភពច្បាប់ផ្សេងទៀតមកបង្គ្រប់ទេ ហើយបើមានតម្រូវការមែននោះត្រូវតែស្របគ្នាទាំងស្រុងទៅនឹងរាល់ឧបករណ៍ច្បាប់ដែលមានស្រាប់នៅអ.វ.ត.ក និងក្នុងប្រព័ន្ធច្បាប់ដែលប្រើប្រាស់ដោយប្រទេសកម្ពុជានិងរាល់ឧបករណ៍ច្បាប់កម្ពុជាទាំងឡាយ តាមមាត្រា១២(១) នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ។

៦១. ការប្រើឧបករណ៍ច្បាប់អន្តរជាតិនានាមកបង្គ្រប់អោយច្បាប់ស្តីពីការបង្កើត អ.វ.ត.ក លុះត្រាតែច្បាប់ប្រើប្រាស់នៅ អ.វ.ត.ក មានខ្វះចន្លោះយ៉ាងជាក់លាក់និងថាឧបករណ៍ច្បាប់អន្តរជាតិដែល អ.វ.ត.ក យកមកប្រើបន្ថែមត្រូវតែស្របជាមួយនឹងប្រព័ន្ធច្បាប់ដែល អ.វ.ត.ក ស្ថិតនៅក្នុងដែនអធិបតេយ្យនៃរដ្ឋដែលប្រើប្រាស់ប្រព័ន្ធច្បាប់នោះ ព្រោះថា អ.វ.ត.ក មិនមែនជាសាលាជម្រះក្តីអន្តរជាតិឯករាជ្យដូចជា ICC នោះទេ តាមការចង្អុលបង្ហាញមាត្រា១២(១)នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជា ។ ជាលទ្ធផល អ.វ.ត.ក ស្ថិតនៅក្នុងដែនអធិបតេយ្យនៃរដ្ឋប្រើប្រាស់ប្រព័ន្ធច្បាប់ Civil Law តាមព្រឹត្តហេតុ ហើយទទួលយកដែនយុត្តាធិការនៃរដ្ឋនោះផងដែរ ។ ការយកមកប្រើនូវប្រព័ន្ធច្បាប់ Common Law របស់អង្គជំនុំជម្រះសាលាដំបូង អ.វ.ត.ក [៣៨] គឺជាការបំផ្លាញចោលទាំងអស់ នៃបទដ្ឋានច្បាប់សំខាន់ៗនៃប្រព័ន្ធច្បាប់ Civil Law ដែលកំពុងប្រើប្រាស់ដោយរដ្ឋដែល អ.វ.ត.ក ស្ថិតនៅក្នុងយុត្តាធិការនេះ និងទាំងបទដ្ឋានច្បាប់ដែលបង្កើតឡើងដោយ អ.ស.ប និង រាជរដ្ឋាភិបាលកម្ពុជាដែលទទួលយកយុត្តាធិការច្បាប់នេះ ។ សរុបសេចក្តីទៅ អ.វ.ត.ក ប្រើប្រាស់ប្រព័ន្ធច្បាប់ Civil Law យ៉ាងពេញលេញដោយឥតប្រកែកបានឡើយ ហេតុនេះគោលការណ៍ដែលថា **គ្មានច្បាប់គឺគ្មានបទល្មើស** ត្រូវតែគោរពតាម (Nullum Crimen Sine Lege)។ តាមន័យនេះ អង្គជំនុំជម្រះធ្វើផ្ទុយទៅនឹងវិធាន២នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ។

---

[៣៧] មាត្រា១នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ និង មាត្រា១ និងមាត្រា២(ថ្មី) នៃច្បាប់ស្តីពីការបង្កើត អវតក ។

[៣៨] សាលក្រមចុះថ្ងៃទី២៦ កក្កដា ២០១០, កថាខណ្ឌ៤៥ ។

៦២. ការប្រើប្រាស់ប្រព័ន្ធស្វ័យពង្រីកអំណាចរបស់អង្គជំនុំជម្រះនៅសាលាដំបូង អ.វ.ត.ក បានប្រឆាំងទៅនឹងមាត្រា៥១(ថ្មី) ជំពូក៤ នៃរដ្ឋធម្មនុញ្ញកម្ពុជាដែលកំណត់ថាអំណាចទាំងបីត្រូវចែកអោយដាច់ពីគ្នា ហើយអង្គជំនុំជម្រះមិនមានសិទ្ធិបង្កើត និង បកស្រាយច្បាប់នេះទេ ។ សិទ្ធិក្នុងការបង្កើតច្បាប់គឺមានតែស្ថាប័ននីតិបញ្ញត្តិតែមួយគត់ ហើយរាល់ការបកស្រាយច្បាប់ គឺជាភារៈកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ។ ហេតុនេះ ការបកស្រាយថាមាត្រា ១ នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្ដីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ មាត្រា១ និងមាត្រា២(ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ដោយអង្គជំនុំជម្រះ អ.វ.ត.ក ថាមិនច្បាស់លាស់[៣៩] ហើយអង្គជំនុំជម្រះមានសិទ្ធិក្នុងការបកស្រាយ និង បង្កើតបញ្ញត្តិបន្ថែមដោយប្រើប្រាស់ទំនៀមទំលាប់អន្តរជាតិដែលកើតចេញពីសាលាជម្រះក្ដី ICTY, ICTR[៤០] គឺមិនត្រឹមត្រូវទេ វាបានប្រឆាំងទៅនឹងគោលការណ៍ជាសកលនៃច្បាប់ដែលកំណត់ថា **គ្មានច្បាប់ គឺគ្មានបទឧក្រិដ្ឋ** (Nullum Crimen Sine Lege) តាមប្រព័ន្ធច្បាប់ Civil Law។

៦៣. ការប្រើប្រាស់ប្រព័ន្ធស្វ័យពង្រីកអំណាចរបស់អង្គជំនុំជម្រះនៅសាលាដំបូង អ.វ.ត.ក នាំអោយអន្តរាយដល់រាល់គោលជំហរម៉ឺងម៉ាត់នៃការបង្កើតសាលាជម្រះក្ដី អ.វ.ត.ក តាមមាត្រា ១ នៃកិច្ចព្រមព្រៀងរវាង អ.ស.ប និងរាជរដ្ឋាភិបាលកម្ពុជា និងមាត្រា១ និងមាត្រា២(ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ហើយវានឹងក្លាយជាគំរូនៃកំហុសឆ្គងធ្ងន់ធ្ងរនៅក្នុងប្រព័ន្ធសាលាជម្រះក្ដីទូទៅនៅកម្ពុជា និងអន្តរជាតិ សំរាប់បច្ចុប្បន្ន និងអនាគត ហើយបំពានទៅនឹងគោលការណ៍ Pacta Sunt Servanda[៤១] ដែលទទួលស្គាល់ដោយមាត្រា២៦ នៃអនុសញ្ញាទីក្រុងវីយែនស្តីពីច្បាប់សន្ធិសញ្ញា។

៦៤. នៅ Tokyo ក៏ដូចជានៅ Nuremberg ដែរ សាលាជម្រះក្ដីអន្តរជាតិទាំងពីរនេះបានហាមឃាត់ និងដាក់កំហិតយ៉ាងតឹងរឹងនិងប្រកបដោយប្រសិទ្ធិភាពដោយមិនអនុញ្ញាតអោយអង្គជំនុំជម្រះប្រើប្រាស់ប្រព័ន្ធស្វ័យ

---

[៣៩] សាលក្រមចុះថ្ងៃទី២៦ កក្កដា ២០១០, កថាខណ្ឌ១៩ ។

[៤០] សាលក្រមចុះថ្ងៃទី២៦ កក្កដា ២០១០, កថាខណ្ឌ២២ ។

[៤១] មាត្រា១នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្ដីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ។

ពង្រីកអំណាចរបស់ខ្លួនបានជាដាច់ខាត[៤២] ។ ជាលទ្ធផលគ្មានកងទ័ពសម្ព័ន្ធមិត្តណាម្នាក់នៅអឺរ៉ុប ត្រូវបានទទួលរងការចោទប្រកាន់ នៅចំពោះមុខសាលាជម្រះក្តី Nuremberg នោះទេ ទោះបីជាទាហានសម្ព័ន្ធមិត្តទាំងនោះបានប្រព្រឹត្តបទឧក្រិដ្ឋកម្មសង្គ្រាមដូចទាហានអាល្លឺម៉ង់ដែរក៏ដោយ ហើយនៅ Tokyo ក៏ដូចគ្នាដែរ គ្មានកងទ័ពអាមេរិកណាម្នាក់ត្រូវទទួលរងការចោទប្រកាន់ ឬជំនុំជម្រះ ពីបទឧក្រិដ្ឋសង្គ្រាមនៅអាស៊ីបូព៌ាទេ ទោះបីជាមានការទំលាក់គ្រាប់បែកជាអាវុធប្រល័យលោក ហើយល្មើសទៅនឹងច្បាប់សង្គ្រាមក៏ដោយ ។

៦៥. យុត្តាធិការនិងបទឧក្រិដ្ឋនៅ ICTY និង ICTR មិនដូចគ្នានឹងយុត្តាធិការនិងបទឧក្រិដ្ឋនៅ អ.វ.ត.ក ទេ ត្បិតយុត្តាធិការនៅ ICTY និង ICTR គ្របដណ្តប់ទាំងស្រុងលើបទឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និង ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ហើយមិនដាក់កំហិតលើយុត្តាធិការអំពីឋានៈបុគ្គលនោះទេ ព្រោះបទឧក្រិដ្ឋនៅទីនោះ គឺកើតចេញពីការរើសអើងជាតិសាសន៍ សាសនា និង ចលនាបំបែករដ្ឋ ហេតុនេះច្បាប់បង្កើត ICTY និង ICTR មិនមានដាក់កំហិតទៅលើឋានៈបុគ្គលដែលប្រព្រឹត្តផ្ទាល់ណាម្នាក់ទេ ។ តែនៅ អ.វ.ត.ក បានដាក់កំហិតទៅលើឋានៈបុគ្គលយ៉ាងច្បាស់[៤៣] ហើយបទឧក្រិដ្ឋកើតឡើងគឺដោយមូលហេតុនយោបាយសុទ្ធសាធ ដែលជាដើមហេតុធ្វើឲ្យច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ដាក់កំហិតទៅលើក្រុមមេដឹកនាំជាន់ខ្ពស់ និងអ្នកទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម គឺសំដៅទៅលើក្រុមបុគ្គលទាំងឡាយណាដែលមានសិទ្ធិសំរេចចិត្តនយោបាយផ្ទាល់ខ្លួន ដែលបង្កើតបានជាគោលនយោបាយបង្កើតបានជាបទឧក្រិដ្ឋ និងដាក់អោយដំណើរការនូវបទឧក្រិដ្ឋកម្មបានសំរេចផល ហើយមិនគ្របដណ្តប់ទៅលើក្រុមជនអនុវត្តតាមបទបញ្ជាប្រព្រឹត្តបទឧក្រិដ្ឋនោះទេ និងមិនមានសិទ្ធិធ្វើសេចក្តីសម្រេចចិត្តផ្ទាល់ខ្លួនបាននោះទេ ។ ហេតុនេះការប្រើប្រាស់ឧបករណ៍ច្បាប់អន្តរជាតិដែលបានមកពីទំនៀមទម្លាប់អន្តរជាតិផ្ទុយពីច្បាប់បង្កើត អ.វ.ត.ក បន្ថែមរបស់អង្គជំនុំជម្រះសាលាដំបូង[៤៤] ក្នុងខណៈដែលច្បាប់ស្តីពីការបង្កើត អ.វ.ត.កមានលក្ខណៈគ្រប់គ្រាន់យ៉ាងនេះ គឺជាការប្រើប្រាស់ប្រព័ន្ធស្វ័យពង្រីកសិទ្ធិអំណាចរបស់អង្គជំនុំ-ជម្រះចេញក្រៅយុត្តាធិការរបស់ខ្លួនតែប៉ុណ្ណោះ ដោយមូលហេតុថាអង្គជំនុំជម្រះទាំងមូលផ្តោតអារម្មណ៍

---

[៤២] មាត្រា៦ នៃច្បាប់ស្តីពីលក្ខន្តិកៈតុលាការអន្តរជាតិ Nuremberg និង មាត្រា៥ នៃធម្មនុញ្ញសាលាជម្រះក្តីយោធាអន្តរជាតិសម្រាប់អាស៊ីបូព៌ា (Tokyo) ។

[៤៣] មាត្រា១ និង មាត្រា២(ថ្មី) នៃច្បាប់ស្តីពីការបង្កើត អវតក ។

[៤៤] សាលក្រមចុះថ្ងៃទី២៦ កក្កដា ២០១០, កថាខណ្ឌ៣០ និង ៣១ ។

តែទៅលើយុត្តាធិការបទល្មើស និងថាអង្គជំនុំជម្រះទាំងមូលបានធ្វើអោយស្កុតចិត្តដោយសារទំហំភាពដ៏ធំនៃបទឧក្រិដ្ឋនិងភាពកាចសាហាវព្រៃផ្សៃរបស់វាជាបច្ច័យសំខាន់ ធ្វើអោយចៅក្រមធ្វើការប្រើប្រាស់ប្រព័ន្ធស្វ័យពង្រីកអំណាចរបស់ខ្លួនក្នុងការចាប់យកជនជាប់ចោទដាក់ក្នុងយុត្តាធិការរបស់ខ្លួនអោយខានតែបាន វាជាការរំលោភទៅនឹងមាត្រា១៤(១)នៃកតិការសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ និងមាត្រា១៣(១)នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាដែលចែងថា ជនគ្រប់រូបមានសិទ្ធិទទួលបាននូវការវិនិច្ឆ័យត្រឹមត្រូវតាមច្បាប់ (Due Process) ។

## II. ឧឡារិករណ៍ទី២: ការភាន់ច្រឡំចំពោះការផ្តន្ទាទោស

### ១. ការភាន់ច្រឡំរបស់អ.ជ.ស.ដ ក្នុងការសំរេចសេចក្តីដោយមិនបានពិនិត្យមើលវិធាន ៨៧ នៃវិធានផ្ទៃក្នុងរបស់អ.វ.ត.ក

៦៦. អង្គជំនុំជម្រះបានខកខានមិនបានពិនិត្យមើលវិធាន៨៧ នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ដោយច្រានចោលសេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទដោយផ្អែកតែទៅលើវិធាន៨៩តែប៉ុណ្ណោះ។ ការច្រានចោលនូវសេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ ដែលពឹងផ្អែកលើភស្តុតាងទាំងស្រុង[៤៥] ដែលបានដាក់ដោយក្រុមព្រះរាជអាជ្ញានៅអង្គជំនុំជម្រះ ហើយទាញចេញពីវិធាន៨៩ទាំងស្រុង គឺបំពានទៅលើវិធាន៨៧ដែលនាំអោយភស្តុតាងដោះបន្ទុកមិនត្រូវបានគេយកមកពិនិត្យទាំងស្រុង ក្នុងការធ្វើអោយប្រាកដថា អ.វ.ត.ក ពិតជាគ្មានយុត្តាធិការលើបុគ្គលជនជាប់ចោទមែនដែរឬទេ តាមការសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ។

៦៧. ការខកខានមិនពិនិត្យមើលវិធាន៨៧ របស់អ.ជ.ស.ដ តាមសេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ គឺជាចេតនាទទួលស្គាល់តាមព្រឹត្តន័យដោយ អ.ជ.ស.ដ ថាជនជាប់ចោទពិតជាមិនមានភស្តុតាងចងភ្ជាប់ទៅនឹងមាត្រា១នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជាមាត្រា១ និងមាត្រា២(ថ្មី) នៃច្បាប់ស្តីពីការបង្កើតអ.វ.ត.កនោះទេ ។ ដោយហេតុនេះហើយបានជាអង្គជំនុំ

---

[៤៥] E3/32 របាយការណ៍ Craig C. Etcheson, ERN 00314778-00314842។

00626059



F114

ជម្រះសាលាដំបូង នៃ អ.វ.ត.ក បានលើកឡើងនៅក្នុងសេចក្តីផ្តើមនៃសាលក្រមរបស់ខ្លួនថ្កោលទោសកិច្ចព្រមព្រៀងរបស់អង្គការសហប្រជាជាតិ ជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជាថារំលោភលើគោលការណ៍ជាសកលនៃច្បាប់[៨៦] គឺ **Jus Cogens** និង គោលការណ៍ដែលថា**គ្មានបទឧក្រិដ្ឋណាដែលឥតច្បាប់ចែង** ដែលត្រូវគេស្រង់ចេញពីប្រភពនៃប្រព័ន្ធច្បាប់ Common Law ដើម្បីបកស្រាយប្រឆាំងទៅនឹងមាត្រា១ នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និង រាជរដ្ឋាភិបាលកម្ពុជា និងមាត្រា១ និងមាត្រា២(ថ្មី) នៃច្បាប់បង្កើត អ.វ.ត.ក ដែលដាក់កំហិតទៅលើសិទ្ធិ និងអំណាចរបស់អង្គជំនុំជម្រះត្រឹមតែទៅលើក្រុមមេដឹកនាំជាន់ខ្ពស់ និងក្រុមជនទាំងឡាយណាដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម ។

៦៨. ការខកខានមិនបានពិនិត្យមើលលើសេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទគឺជាការខកខានមិនបានពិនិត្យមើលភស្តុតាងដោះបន្ទុកដែលជាដើមហេតុនាំអោយមានវិមតិសង្ស័យ។ គឺផ្ទុយទៅនឹង វិធាន៨៧(១) នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះសម្រេចដោយពឹងផ្អែកលើភស្តុតាងច្បាស់លាស់ និងគ្មានវិមតិសង្ស័យ។ តាមមាត្រា៣៨ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា **រាល់វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ**។

៦៩. ការសម្រេចផ្តន្ទាទោសជនជាប់ចោទ គឺពឹងផ្អែកតែទៅលើភស្តុតាងដាក់បន្ទុកលើបទល្មើស ហើយខកខានមិនបានពិនិត្យមើលលើភស្តុតាងដោះបន្ទុកលើយុត្តាធិការបុគ្គលទាំងស្រុង[៨៧] ដែលលើកឡើងដោយមេធាវីការពារជនជាប់ចោទ ជាលទ្ធផលអង្គជំនុំជម្រះប្រើប្រាស់សច្ចធារណ៍ហួសហេតុ ដោយពោលថាយល់ស្របតាមព្រះរាជអាជ្ញា ហើយមិនបានលើកសំអាងហេតុណាមួយមកធ្វើជាអំណះអំណាងគួរអោយជឿបានដោយគ្មានវិមតិសង្ស័យលើរាល់ភស្តុតាងដែលខ្លួនបានប្រើប្រាស់ធ្វើជាសំអាងហេតុក្នុងការកំណត់អំពីយុត្តាធិការ-របស់ខ្លួនលើជនជាប់ចោទ ។

៧០. ការខកខានមិនបានពិនិត្យមើលវិធាន៨៧(១) ដោយអង្គជំនុំជម្រះសាលាដំបូង នាំអោយអង្គជំនុំជម្រះបំពានលើមាត្រា២៩០(៦) នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដែលចែងថា ប្រសិនបើតុលាការ

---

[៨៦] សាលក្រមចុះថ្ងៃទី២៦ កក្កដា ២០១០, កថាខណ្ឌ៣០ និង ៣១ ។

[៨៧] សាលក្រមចុះថ្ងៃទី២៦ កក្កដា ២០១០, កថាខណ្ឌ១៧ និង ១៨ ។

ដែលទទួលពាក្យបណ្តឹងយល់ឃើញថាពុំមានសមត្ថកិច្ចតាមដែនដី តុលាការនេះប្រកាសថាពុំមានសមត្ថកិច្ចដោយសាលក្រម ។ មាត្រា២៨០(៦) នេះក៏អាចត្រូវបានគេមើលឃើញវាដូចគ្នាផងដែរ ដែលសាលាដំបូងនៃ អ.វ.ត.ក អាចយកមកប្រើបានបើសិនជាខ្លួនបានពិនិត្យមើលភស្តុតាងតាមសេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ ហើយយល់ស្របថាពិតជាគ្មានយុត្តាធិការលើបុគ្គលជនជាប់ចោទប្រាកដមែននោះ។ ការលើកយកវិធាន៨៩នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក មកទាត់ចោលសេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ វាបង្ហាញអោយឃើញថាអង្គជំនុំជម្រះក៏យល់ឃើញស្របដូចការលើកឡើងរបស់មេធាវីការពារជនចាប់ចោទ ថាជនជាប់ចោទមិនស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក ទេ តែគ្រាន់តែការលើកឡើងរបស់មេធាវីយឺតពេលតែប៉ុណ្ណោះ ហេតុនេះសាលាដំបូងនៃ អ.វ.ត.ក ត្រូវតែប្រកាសថាពុំមានសមត្ថកិច្ចដោយសាលក្រមដូចមាត្រា ២៨០(៦) នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដែលមានស្រាប់ ។ ហេតុនេះការលើកឡើងដោយ មេធាវីការពារជនជាប់ចោទនៅក្នុងសេចក្តីសន្និដ្ឋានរបស់ខ្លួនជូនអង្គជំនុំជម្រះសាលាដំបូង នៃ អ.វ.ត.ក ថា ជនជាប់មិនស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក មិនអាចត្រូវបានច្រានចោលដោយសំអាងថាលើកឡើងយឺតពេលនោះទេ ព្រោះសេចក្តីសំអាងទាំងអស់ដែលលើកឡើងដោយមេធាវីការពារជនជាប់ចោទ គឺទាញចេញពីវិធាន ៨៧(១) ទាំងស្រុង ហើយអង្គជំនុំជម្រះក៏នៅតែអាចប្រើមាត្រា២៨០(៦) នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដែលមានតម្លៃប្រហែលគ្នាមកប្រើក្នុងការប្រកាសថា ពុំមានសមត្ថកិច្ចដោយសាលក្រមបានដែរ ស្របតាមមាត្រា១២(១) នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និង រាជរដ្ឋាភិបាលកម្ពុជា ។

៧១. អង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក ខកខានមិនបានពិនិត្យមើលសេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ គឺបានបំពានវិធាន ៩២ និង វិធាន ៩៣ នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ទាំងស្រុង ហើយប្រើប្រាស់វិធាន ៨៩ ដោយខុសពេលវេលា និងខុសឆ្គងនីតិវិធី ។ វាមានភស្តុតាងដោះបន្ទុកសំខាន់ៗទាក់ទងទៅនឹងឋានៈបុគ្គលរបស់ជនជាប់ចោទដែលត្រូវបានបង្ហាញដោយជនជាប់ចោទផង[៤៨] និងទាំងភស្តុតាងដាក់ដោយក្រុមព្រះរាជអាជ្ញាផង[៤៩] ដែលស្របទៅតាមមាត្រា ១ នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និង រាជរដ្ឋាភិបាលកម្ពុជា និងមាត្រា១ និង មាត្រា២(ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ។ ប៉ុន្តែជាអកុសលវាមិន

[៤៨] កំណត់ហេតុសួរចម្លើយ ឌុច ពី E3/23 ដល់ E3/41 សំណុំរឿងលេខ០០១ ។

[៤៩] E3/32 របាយការណ៍ Craig C. Etcheson ។

ត្រូវបានលើកមកពិនិត្យដោយអង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក នេះគឺជាកំហុសឆ្គងដ៏ធំមួយ ។ នៅតុលាការកំពូលប្រទេសកាណាដា ធ្លាប់បានលើកឡើងពីកំហុសឆ្គងនៃការមិនពិនិត្យមើលភស្តុតាងលើលក្ខខណ្ឌយុត្តាធិការពេលជំនុំជម្រះរបស់សាលាដំបូងប្រទេសកាណាដាផងដែរ ដែលផ្តោតខ្លាំងពេកតែទៅលើយុត្តាធិការបទល្មើស[៥០] ។ តុលាការកំពូលប្រទេសកាណាដា បានលើកឡើងថាលក្ខខណ្ឌយុត្តាធិការមិនចាំបាច់បង្ហាញថាហួសពីវិមតិសង្ស័យទេ ។ ប៉ុន្តែចៅក្រមជំនុំជម្រះត្រូវតែពិចារណាពីភស្តុតាងដើម្បីបំពេញតាមយុត្តាធិការ ហើយចៅក្រមជំនុំជម្រះមិនគ្រាន់តែផ្អែកតែទៅលើការវាយតម្លៃរបស់ខ្លួនចំពោះលក្ខខណ្ឌទាំងនេះ តែទៅលើបទចោទ ដែលគេបានធ្វើឡើងនោះឡើយ ។ ដោយសារតែអង្គហេតុមួយចំនួនដែលចាំបាច់ក្នុងការបង្កើតយុត្តាធិការមិនដូចគ្នា នឹងអង្គហេតុដែលចាំបាច់សម្រាប់គណៈវិនិច្ឆ័យ សម្រាប់ការសម្រេចរបស់គណៈវិនិច្ឆ័យលើបទល្មើសដែលកំពុងកើតឡើងនោះ រាល់សេចក្តីសម្រេចមិនអាចធ្វើឡើងដោយគណៈវិនិច្ឆ័យបានទេ។ ដូចដែលចៅក្រមជំនុំជម្រះពិនិត្យមើលភស្តុតាងទាក់ទងទៅនឹងបញ្ហាយុត្តាធិការដែរនោះ ជាទូទៅវានឹងមានប្រសិទ្ធិភាពជាង ប្រសិនបើឲ្យចៅក្រមជំនុំជម្រះគិតពិចារណាពីបញ្ហាយុត្តាធិការស្របគ្នានឹងពេលដែលគណៈវិនិច្ឆ័យពិនិត្យមើលភស្តុតាងដែលទាក់ទងនឹងបទល្មើសដែរ ។ ទាំងអស់នេះជាការបង្ហាញអោយឃើញថា ភស្តុតាងដែលចង្អុលបង្ហាញយុត្តាធិការរបស់សាលាជម្រះក្តីនៅតែមានសារប្រយោជន៍ និងត្រូវបានគេលើកយកមកបង្ហាញនិងទាញជាអំណះអំណាងបានគ្រប់ពេលវេលា ដោយពឹងផ្អែកទៅលើសក្ខីកម្មផ្តល់ដោយអ្នកជំនាញការ ឬសាក្សីដ៏មានសក្តានុពលនានា ។ ការទាត់ចោលភស្តុតាងចង្អុលបង្ហាញពីបញ្ហាយុត្តាធិការសាលាជម្រះក្តី ដោយការលើកឡើងថាមិនបានលើកឡើងទាន់ពេលវេលាមិនអាចទទួលយកបានតាមបណ្តាប្រព័ន្ធតុលាការនៅអរិយប្រទេសមួយចំនួន ។

### ក. ភស្តុតាងដោះបន្ទុកដែលមិនទាន់បានបង្ហាញដោយអង្គជំនុំជម្រះ

៧២. របាយការណ៍ដែលផ្តល់ដោយអ្នកជំនាញ Craig C. Etcheson អ្នកស៊ើបអង្កេតនៅការិយាល័យសហព្រះរាជអាជ្ញា[៥១]។

---

[៥០] រឿងក្តីនៅតុលាការកំពូលប្រទេស កាណាដា R v Finta, [1994] 1.S.C.R.701 Her Majesty the queen V Imire Finta ត្រូវបានចោទប្រកាន់ក្នុងបទឧក្រិដ្ឋកម្មសង្គ្រាម និង ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងអំឡុងពេល Nazi គ្រប់គ្រងអឺរ៉ុបក្នុងសម័យសង្គ្រាមលោកលើកទី២ ។ Case Nos. 23023,23097. 1993, June, 2,3; 1994, March 24 ។

[៥១] E3/32 របាយការណ៍ Craig C. Etcheson, ERN 00314778 ។

F14

## (១) អំពីបញ្ហាបុគ្គល និងបញ្ហានៃការចាត់តាំង

៧៣. ការកំណត់អំពីមេដឹកនាំជាន់ខ្ពស់ និងអ្នកទទួលខុសត្រូវបទឧក្រិដ្ឋខ្ពស់បំផុតរបស់របបកម្ពុជាប្រជាធិបតេយ្យនិងបក្សកុម្មុយនីស្តកម្ពុជា ។

៧៤. មន្ទីរធំបំផុតសំរាប់ប្រតិបត្តិថ្នាក់មជ្ឈិមគឺប្រើលេខសំគាល់ ៨៧០ ហើយមន្ទីរនេះបែងចែកជាក្រុម ដែលមានកំណត់អក្សរ "ក" សំរាប់សំគាល់ ហើយមន្ទីរដែលមានកំណត់អក្សរ "ក" សំគាល់គឺស្ថិតនៅក្រោមការគ្រប់គ្រងរបស់មន្ទីរមួយទៀត ហៅថាមន្ទីរ ស-៧១ ។ មន្ទីរសំខាន់ដែលកំណត់ដោយអក្សរ "ក" មាន ៖ ក១ ក២ ក៣ ក៤ ក៥..................ក២០ [៥២] ។

៧៥. ការកំណត់ពីរចនាសម្ព័ន្ធគណៈអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជា និងបានបង្ហាញច្បាស់ពីការត្រួតត្រាមន្ត្រីជាន់ខ្ពស់ទាំងអស់ក្នុងតំណែងបក្ស រដ្ឋាភិបាល និងយោធា [៥៣] ។

៧៦. គណៈអចិន្ត្រៃយ៍មានទំនាក់ទំនងផ្ទាល់ជាមួយបុគ្គលិកពីតាមតំបន់ ស្រុក និងថ្នាក់សាខាផងដែរ [៥៤] ។

៧៧. សេចក្តីសំរេចរបស់មជ្ឈិមអំពីបញ្ហាផ្សេងៗមួយចំនួន ។ សិទ្ធិសំរេចកំទេចក្នុងជួរ និង ក្រៅជួរ [៥៥] ។

---

[៥២] E3/32 របាយការណ៍ Craig C. Etcheson, កថាខណ្ឌ ១៤, ERN 00314781-00314783 ។

[៥៣] E3/32 របាយការណ៍ Craig C. Etcheson, កថាខណ្ឌ ១៥, ១៦, ១៧ និង ១៨, ERN 00314783-00314784 ។

[៥៤] E3/32 របាយការណ៍ Craig C. Etcheson, កថាខណ្ឌ ២១ , ERN 00314786 ។

[៥៥] សេចក្តីសំរេចរបស់មជ្ឈិម, ERN 00003136 -00003142 ។

P114

## (២) អំពីសន្តិសុខ

៧៨. គណៈអចិន្ត្រៃយ៍ដើរតួម្តងទៀត ក្នុងនាមគណៈមជ្ឈិមមានអំណាចអនុញ្ញាតអោយអង្គការថ្នាក់ក្រោមជាឧបករណ៍របស់បក្សអនុវត្តទោសប្រហារជីវិតដូចក្នុងសេចក្តីសម្រេចថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ [៥៦] ។ គណៈភូមិភាគមានអំណាច "គ្រប់គ្រងវិន័យក្នុងក្របខណ្ឌភូមិភាគ" ។ គណៈអចិន្ត្រៃយ៍ភូមិភាគ ជាអ្នកធ្វើសេចក្តីសំរេចគឺ ក្នុងន័យនេះគណៈភូមិភាគជាអ្នកសំរេចកំទេចនរណាក៏បាន [៥៧]។

## (៣) ទំនាក់ទំនងភូមិភាគ

៧៩. គណៈភូមិភាគបានទំនាក់ទំនងជាទៀងទាត់ជាមួយតំបន់ ស្រុក និងឃុំទាំងឡាយជាមួយមជ្ឈិម [៥៨]។

## (៤) គណៈយោធាមជ្ឈិមបក្ស [៥៩]

៨០. ប៉ុល ពត ប្រធាន

នួន ជា អនុប្រធានទទួលបន្ទុកបញ្ជានយោបាយ

អ៊ុង ជឿន (តាម៉ុក) អនុប្រធានទទួលបន្ទុកកិច្ចការយោធា

វ៉ាន់ សមាជិកគណៈយោធាមជ្ឈិម

ខៀវ សមាជិកគណៈយោធាមជ្ឈិម ... ប្រធានក្រុមប្រឹក្សាសេនាធិការ

---

[៥៦] E3/32 របាយការណ៍ Craig C. Etcheson, កថាខណ្ឌ ២៤, ERN 00314787 ។

[៥៧] E3/32 របាយការណ៍ Craig C. Etcheson, កថាខណ្ឌ ៤៦, ERN 00314797 ។

[៥៨] E3/32 របាយការណ៍ Craig C. Etcheson, កថាខណ្ឌ ៥៥, ERN 00314800 ។

[៥៩] E3/32 របាយការណ៍ Craig C. Etcheson, កថាខណ្ឌ ៩៩, ERN 00314817- 00314818 ។

## (៥) គណៈយោធាមជ្ឈិមបក្ស [៦០]




## (៦) អគ្គសេនាធិការ [៦១]

៨១. អគ្គសេនាធិការកងទ័ពបដិវត្តកម្ពុជា ក្រោមការគ្រប់គ្រងរបស់ **សុន សេន** ហៅ **ខៀវ** ហៅ **បង៨៩** អនុវត្តមុខងារប្រកបដោយស្តង់ដារនៃមន្ទីរយោធារួមមាន ប្រតិបត្តិការ ស៊ើបការសំងាត់ និងភស្តុភា ។ អ្នកដែលជាមេដឹកនាំចំណុះអោយអគ្គសេនាធិការពី៣១១នាក់ ដល់៣២៦នាក់ ។

[៦០] E3/32 របាយការណ៍ Craig C. Etcheson, កថាខណ្ឌ ១០០, ERN 00314818 ។

[៦១] E3/32 របាយការណ៍ Craig C. Etcheson, កថាខណ្ឌ ១០៨, ERN 00314821 ។

F14

## (៧) អគ្គសេនាធិការកងទ័ពបដិវត្តកម្ពុជា [៦២]




៨២. កងទ័ពបដិវត្តត្រូវបែងចែកជា ៩កងពលធំ មាន (កងពលធំលេខ៧០៣ ៣១០ ៤៥០ ១៧០ ២៩០ ៥០២ ៨០១ ៩២០ និង១៦៤) និងកងវរសេនាធំឯករាជ្យចំនួន៣ គឺ (កងវរសេនាធំលេខ ១៥២ ៤៨៨ និង៣៧៧) និងមន្ទីរមួយចំនួនទៀតគឺ (មន្ទីរស-២១ ម-៦៣ និង ម-៦២) [៦៣]។

---

[៦២] E3/32 របាយការណ៍ Craig C. Etcheson, កថាខណ្ឌ ១០៩ , ERN 00314821-00314822 ។

[៦៣] E3/32 របាយការណ៍ Craig C. Etcheson, កថាខណ្ឌ ១១៥, ERN 00314824 ។

F14

## (៨) កងពលធំ និងវរសេនាធំឯករាជ្យនៃកងទ័ពបដិវត្តកម្ពុជា [៦៤]

## គណៈយោធាមជ្ឈិម




៨៣. ថ្នាក់ដឹកនាំបក្សបានបញ្ជាក់ថា "តួនាទីស្នូលរបស់កងទ័ពបដិវត្តគឺការពារប្រទេស និងសន្តិសុខផ្ទៃក្នុងប្រទេស" ។ មន្ទីរ ស-២១ ជាអង្គភាពដំបូងពាក់ព័ន្ធនឹងប្រតិបត្តិការសន្តិសុខផ្ទៃក្នុង ហើយមានបញ្ជីឈ្មោះជាផ្នែកមួយនៃកងទ័ពបដិវត្តកម្ពុជា ។ អ្នកដឹកនាំបក្សកុម្មុយនីស្តកម្ពុជាបានកត់សំគាល់ថាមានបក្សប៉ុណ្ណោះទើបដឹកនាំកងទ័ពបាន គ្មានអង្គភាពផ្សេង ឬបុគ្គលរូបណាអាចដឹកនាំបានឡើយ [៦៥]។

---

៦៤ E3/32 របាយការណ៍ Craig C. Etcheson, កថាខណ្ឌ ១១៦, ERN 00314824-00314825 ។

៦៥ E3/32 របាយការណ៍ Craig C. Etcheson, កថាខណ្ឌ ១១៧ , ERN 00314825 ។

៨៤. មេបញ្ជាការកងពលលេខ៥០២ ឈ្មោះ ស៊ូ ម៉េត បានប្រកាសពីការចាប់ខ្លួនសមាសភាពខ្លាំងបញ្ជូនមក ស-២១ ។ ស៊ូ ម៉េត ជាអ្នកធ្វើសេចក្តីសំរេចចិត្តបញ្ជូនមនុស្សមក ស-២១ ឬសម្លាប់ចោល [៦៦] ។ ស៊ូ ម៉េត បញ្ជាអោយកងពលធំលេខ ៥០២ មានសិទ្ធិបោសសំអាតខ្មាំងក្នុងអង្គភាពរបស់អង្គការ គាត់បញ្ជាអោយចាប់ខ្លួន និងបញ្ជូនមក ស-២១ [៦៧]។

## (៩) ក្រសួងនានា [៦៨]

១-សមមិត្តលេខា: ទទួលខុសត្រូវលើយោធា និងសេដ្ឋកិច្ច

២-សមមិត្តលេខារង: កិច្ចការបក្ស សកម្មភាពសង្គម វប្បធម៌ ឃោសនា និងអប់រំ ។

៣-សមមិត្ត វ៉ាន់: កិច្ចការបរទេស ទាំងបក្សទាំងរដ្ឋ

៤-សមមិត្ត ហែម: ទទួលខុសត្រូវចំពោះរណៈសិរ្ស និងរដ្ឋាភិបាល និងពាណិជ្ជកម្មសំរាប់គណនេយ្យ និងតម្លៃ ។

៥-សមមិត្ត ឌុច: ពាណិជ្ជកម្មក្នុងស្រុក និងអន្តរជាតិ ។

៦-សមមិត្ត ខៀវ: ទទួលខុសត្រូវអគ្គសេនាធិការ និងសន្តិសុខ

៧-សមមិត្ត វន: ឧស្សាហកម្ម ផ្លូវដែក និង ជលផល

៨-សមមិត្ត ឌឿន: ប្រធានមន្ទីរនយោបាយ ៨៧០

៩-សមមិត្ត ភា: ទទួលខុសត្រូវចំពោះវប្បធម៌ សកម្មភាពសង្គម និងកិច្ចការបរទេស ។

១០-សមមិត្ត អាត: ឃោសនា និងអប់រំ ទាំងផ្ទៃក្នុងនិងខាងក្រៅ ។

១១-សមមិត្ត ជ័យ: កសិកម្ម

១២-សមមិត្ត យ៉ែម: មន្ទីរ ៨៧០

១៣-សម ប៉ង់: មន្ទីររដ្ឋាភិបាល ។

---

[៦៦] E3/32 របាយការណ៍ Craig C. Etcheson, កថាខណ្ឌ ១២២ , ERN 00314827 ។

[៦៧] E3/32 របាយការណ៍ Craig C. Etcheson, កថាខណ្ឌ ១២៣ , ERN 00314827 ។

[៦៨] E3/32 របាយការណ៍ Craig C. Etcheson, កថាខណ្ឌ ១២៩ , ERN 00314831 ។

៨៥. សរុបសេចក្តីទៅ ស-២១ មាន **កាំង ហ្កេកអ៊ាវ** ហៅ**ឌុច** ជាប្រធានគ្រប់គ្រងផ្នែកសន្តិបាល និងកិច្ចការនយោបាយ ។ **កាំង ហ្កេកអ៊ាវ** ហៅ **ឌុច** មានភារកិច្ចទទួលបញ្ជាពីអគ្គសេនាធិការកងទ័ពបដិវត្ត ដើម្បីផ្សព្វផ្សាយបទបញ្ជាទៅថ្នាក់ក្រោម និងធ្វើសេចក្តីរាយការណ៍អោយថ្នាក់លើវិញ ជាតួនាទីកងទ័ពទាបជាងគេក្នុងចំណោមកម្មាភិបាលកងទ័ពបដិវត្តនៅក្នុងក្រសួងការពារជាតិ និងស្ថិតនៅក្រោមអគ្គសេនាធិការ និងសេនាធិការកងទ័ព ។

៨៦. ឯខាងផ្នែករដ្ឋបាល ស-២១ ត្រូវស្ថិតនៅក្រោម ស-៧១ ដែលមាន ប៉ង់ ជាប្រធាន ហើយមន្ទីរ ស-៧១ នេះគ្រប់គ្រងក្រសួងទាំងអស់ ព្រោះថានៅជាមួយមន្ទីរ ក១ ដែលជាកន្លែងធ្វើការរបស់មជ្ឈិមបក្សផង និងនាយករដ្ឋមន្ត្រីផង ។ ប្រធានស-២១ គ្មានសិទ្ធិធ្វើសេចក្តីសំរេចចិត្តផ្ទាល់ខ្លួនទេ ។ ចំពោះឋានានុក្រមក្នុងជួរបក្សកុម្មុយនីស្តកម្ពុជាគឺឋានៈលេខាមន្ទីរ ស-២១ ស្មើនឹងឋានៈលេខាកងវរសេនាធំ តែប៉ុណ្ណោះ គឺជាឋានៈសាខាបក្សទាបជាងគេបង្អស់ នៅក្នុងសាខាបក្សកុម្មុយនីស្តកម្ពុជា ។

## ខ. ប្រភពភស្តុតាងបន្ថែម

### (១) ប្រភពបានមកពី DC-Cam

- តាមសេចក្តីសន្និដ្ឋានរបស់ DC-Cam ដាក់ជូនគណៈកម្មការជំនាញរបស់ UN

  ១- **កាំង ហ្កេកអ៊ាវ** គឺជាប្រធានសន្តិបាលនៃ ស-២១ ហើយអ្នកទទួលខុសត្រូវជាន់ខ្ពស់គឺ សុន សេន និង ប៉ុល ពត ។

### (២) ប្រភពបានមកពីអ្នកជំនាញ Craig C. Etcheson

- តាមសេចក្ដីសន្និដ្ឋានរបស់អ្នកជំនាញការអោយការិយាល័យសហព្រះរាជអាជ្ញាគឺលោក Craig C. Etcheson បង្ហាញថាស-២១ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងការពារជាតិរបស់កម្ពុជាប្រជាធិបតេយ្យយ៉ាងពិតប្រាកដ [៦៩] ។

១-ក្រោមបញ្ជាផ្ទាល់របស់អគ្គសេនាធិការដែលមាន សុន សេន ជាប្រធានក្រោមក្រសួងការពារជាតិ ដែលមាន សុន សេន ជារដ្ឋមន្ត្រី ។

២-ក្រោមបញ្ជានាយករដ្ឋមន្ត្រីដែលមាន ប៉ុល ពត ជានាយករដ្ឋមន្ត្រី មានក្រុមជំនួយការសេនាធិការ ជាអ្នកទទួលអនុវត្តបទបញ្ជាគឺមាន ប៉ង់, លឹន ជាអ្នកទទួលខុសត្រូវ ហៅថា ស-៧១ ។

៣-ក្រោមបញ្ជារបស់ នួន ជា ជាអគ្គត្រួតពិនិត្យរបស់ ប៉ុល ពត និងជាសមាជិកគណៈយោធាមជ្ឈិម ។

៤-ក្រោមកិច្ចការពារសន្តិសុខពីកងពល ៧០៣ ។

## (៣) ប្រភពបានមកពីសេចក្ដីសារភាពរបស់ជនជាប់ចោទ

- សេចក្ដីសារភាពរបស់ **កាំង ហ្គេកអ៊ាវ** ហៅ **ឌុច** អំពីភារៈកិច្ចនៅ ស-២១

១-ត្រួតពិនិត្យកិច្ចការរដ្ឋបាល

២-ត្រួតពិនិត្យមើលចំលើយសារភាព សង្ខេបរាយការទៅ **សុន សេន** , **នួន ជា**

៣-ទទួលបញ្ជាថ្នាក់លើមកផ្សព្វផ្សាយ និងធ្វើសេចក្ដីរាយការណ៍ទៅថ្នាក់លើវិញ

៤-សិទ្ធិសំរេចគឺជាសិទ្ធិប្រទានរបស់ **សុន សេន** ឬ **នួន ជា**

- លក្ខណៈពិសេសរបស់ ស-២១ គឺមន្ទីរនេះគ្រប់គ្រងដោយផ្ទាល់ពីគណៈកម្មាធិការមជ្ឈិមតាមសេចក្ដីសំរេចរបស់គណៈអចិន្ត្រៃយ៍ [៧០]។

- **កាំង ហ្គេកអ៊ាវ** ហៅ **ឌុច** ជាប្រធានស-២១ មិនអាចធ្វើការទាក់ទងអង្គភាពផ្សេងដើម្បីចាប់ខ្លួននោះបានទេ វាជាវិន័យមិនអាចបំពានបានទេ [៧១] ។

---

[៦៩] E3/32 របាយការណ៍ Craig C. Etcheson, កថាខណ្ឌ ១៣៣, ERN 00314833-00314834 ។

[៧០] E3/217 , កំណត់ហេតុនៃការសួរចំលើយរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០០៨ ទំព័រ៣, ERN 00178047 (ខ្មែរ)។

00626070



F114

៨៧. ភស្តុតាងដែលថា **កាំង ហ្កេកអ៊ាវ** ហៅ **ឌុច** គ្មានសិទ្ធិធ្វើការសំរេចចិត្តដោយខ្លួនឯងក្នុងការបង្កើត និងរៀបចំដំណើរការ ស-២១ រួមទាំងបទឧក្រិដ្ឋទាំងឡាយដែលកើតនៅ ស-២១ ផងដែរ [៧២]។

៨៨. ភស្តុតាងដែលថា **កាំង ហ្កេកអ៊ាវ** ហៅ **ឌុច** គ្មានសិទ្ធិធ្វើការសំរេចចិត្តដោយខ្លួនឯងក្នុងការបង្កើត និងរៀបចំដំណើរការ ស-២១ សូម្បីតែផ្នែករដ្ឋបាល [៧៣]។

៨៩. ភស្តុតាងដែលថា **កាំង ហ្កេកអ៊ាវ** ហៅ **ឌុច** គ្មានសិទ្ធិធ្វើការសំរេចចិត្តដោយខ្លួនឯងក្នុងការបង្កើត និងរៀបចំដំណើរការ ស-២១ **ឌុច** គ្មានកំលាំងក្រោមបង្គាប់ផ្ទាល់ខ្លួនទេ ក្រៅពីបុគ្គលិកនៅក្នុង ស-២១ ផ្ទាល់ ។ ហើយភារកិច្ចការពារសន្តិសុខលើ ស-២១ ទាំងមូលគឺជាភារកិច្ចរបស់កងពលលេខ៥០២ [៧៤]។

៩០. ភស្តុតាងដែលបញ្ជាក់ថា **ឌុច** គ្មានសិទ្ធិធ្វើសេចក្តីសម្រេចចិត្តដោយឯករាជ្យ គឺដូចជាករណីមានការរំលោភអ្នកទោសស្រី ....ដោយក្រុមសួរចម្លើយពេលនោះ **ឌុច** បានព្យាយាមបញ្ឈប់ ដោយរាយការទៅថ្នាក់លើគឺ **សុន សេន** តែគ្មានបានទទួលលទ្ធផលវិជ្ជមានទេ នៅទីបំផុត **ឌុច** ពិតជាមិនអាចធ្វើសេចក្តីសម្រេចចិត្តផ្ទាល់ខ្លួនបានទេក្នុងការបញ្ឈប់បទឧក្រិដ្ឋណាមួយដែលកើតមាននៅ ស-២១ បានទេ។ នេះជាភស្តុតាងបញ្ជាក់ថា **ឌុច** មិនមែនជាក្រុមដែលទទួលខុសត្រូវខ្ពស់បំផុត ចំពោះបទឧក្រិដ្ឋនៅស-២១ទេ។

## ២. ការគោរពច្បាប់របស់ អ.វ.ត.ក ក្នុងការសំរេចសេចក្តីដោយផ្តន្ទាទោសជនជាប់ចោទតាមឆន្ទៈសេរី

---

[៧១] E3/217, កំណត់ហេតុនៃការសួរចម្លើយ ឌុច ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០០៨ ទំព័រ៧, ERN 00178051 (ខ្មែរ) ។

[៧២] ចម្លើយសារភាពរបស់ទាញ , ERN 00025620(ខ្មែរ) ។

[៧៣] ឯកសារ D91/I , ERN 00002455 (ខ្មែរ)។

[៧៤] រចនាសម្ព័ន្ធគ្រប់គ្រងបញ្ជាលើ ស-២១"គុកសម្ងាត់ឃោធា" ហៅ គុកទួលស្លែង របស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ពីខែ មីនា ១៩៧៦ ដល់ថ្ងៃទី១៥ សីហា ១៩៧៧ និងពីថ្ងៃទី១៥ សីហា ១៩៧៧ ដល់ថ្ងៃទី០៦ មករា ១៩៧៩ (ភ្ជាប់ជាមួយ ឧបសម្ព័ន្ធ ក)។

៩១. មិនត្រឹមតែអ.ជ.ស.ដ មានកំហុសឆ្គងដែលមិនបានពិនិត្យនូវវិធាន ៨៧ នៃវិធានផ្ទៃក្នុងរបស់អ.វ.ត.ក មុននឹងធ្វើការសំរេចទៅលើ **កាំង ហ្កេកអ៊ាវ** ហៅ**ឌុច** ប៉ុណ្ណោះទេ និងទោះបីជាមានមតិជំទាស់របស់ចៅក្រមអន្តជាតិ១(មួយ)រូប[៧៥] ដែលជាសមាសភាពរបស់អ.ជ.ស.ដ បានជំទាស់អំពីការកំណត់ទោសរួមទៅលើ **កាំង ហ្កេកអ៊ាវ** ហៅ**ឌុច** យ៉ាងណាក៏ដោយ ក៏ចៅក្រម នៃ អ.ជ.ស.ដ ផ្សេងទៀត បានប្រើឆន្ទានុសិទ្ធិរបស់ខ្លួនធ្វើការកំណត់ទោសរួមទៅលើ **កាំង ហ្កេកអ៊ាវ** ហៅ**ឌុច** តាមទំនើងចិត្ត ដោយមិនបានគោរពនូវមាត្រា ៩៥ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដែលចូលជាធរមានរួចហើយនោះទេ បែជាប្រើឆន្ទានុសិទ្ធិដោយផ្អែកទៅលើយុត្តិសាស្ត្រអន្តរជាតិ[៧៦] យកមកធ្វើជាអំណះអំណាងក្នុងការកំណត់ទោសរួមទៅលើ **កាំង ហ្កេកអ៊ាវ** ហៅ **ឌុច** ទៅវិញ ។

៩២. នេះជាការកត់សំគាល់បន្ទាប់បន្សំដែលមេធាវីការពារក្តីជនជាប់ចោទលើកឡើង ដើម្បីឲ្យអង្គជំនុំជម្រះតុលាការកំពូលមេត្តាពិចារណាទៅលើអង្គច្បាប់ និងគោលការណ៍ច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា ដែលមានចែង និងបានកំណត់យ៉ាងច្បាស់លាស់រួចហើយ ។

## សេចក្តីសន្និដ្ឋានជាទូទៅ

៩៣. តាំងតែពីការស៊ើបអង្កេតជាបឋម រហូតមកដល់សហព្រះរាជអាជ្ញាខកខានមិនបានស៊ើបអង្កេតពីអ្នកទទួលខុសត្រូវជាន់ខ្ពស់ និងក្រុមអ្នកទទួលខុសត្រូវខ្ពស់បំផុតលើឧក្រិដ្ឋកម្មនៅមន្ទីរស-២១ (គុកទួលស្លែង) ក្រៅពីការស៊ើបអង្កេតពីឋានៈ និង សកម្មភាពរបស់ **កាំង ហ្កេកអ៊ាវ** ហៅ**ឌុច** នៅគុកទួលស្លែងចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ដែលជាដើមហេតុនាំឲ្យភាន់ច្រឡំថា **កាំង ហ្កេកអ៊ាវ** ហៅ **ឌុច** ជាអ្នកទទួលខុសត្រូវលើឧក្រិដ្ឋកម្មខ្ពស់បំផុតនៅមន្ទីរស-២១ ឬ គុកទួលស្លែង ហើយធ្វើឲ្យ **ឌុច** និង ទាំងមេធាវីមិនអាចផ្តល់ភស្តុតាងជំទាស់ដោះបន្ទុកដោយផ្ទាល់ភ្លាមៗបាន ហើយនាំអោយសហព្រះរាជអាជ្ញាយល់ច្រឡំថាសាលាជំរះក្តី អ.វ.ត.ក មានយុត្តាធិការលើរូប **ឌុច** ត្រង់ចំណុចចោទថាជាអ្នកទទួលខុសត្រូវខ្ពស់បំផុតលើឧក្រិដ្ឋកម្ម ។ សហព្រះរាជអាជ្ញាក៏ធ្លាប់មានការយល់ច្រឡំថា **ឌុច** ជា

---

[៧៥] មតិជំទាស់របស់ចៅក្រម Jean-Marc LAVERGNE ,កថាខណ្ឌ ២-៩, ឯកសារ E188.1។

[៧៦] សាលក្រមចុះថ្ងៃទី២៦ កក្កដា ២០១០, កថាខណ្ឌ ៥៩១ ។

00626072



F14

មេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យផងដែរ[៧៧] ហើយសហចៅក្រមស៊ើបសួរ បានធ្វើដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដោយបានកែប្រែបទចោទមកជាអ្នកទទួលខុសត្រូវខ្ពស់បំផុតលើបទឧក្រិដ្ឋទៅវិញ[៧៨]។ នេះជាភស្តុតាងបញ្ជាក់ថា ទាំងសហព្រះរាជអាជ្ញា ទាំងសហចៅក្រមស៊ើបសួរ សុទ្ធតែគ្មានមូលដ្ឋានច្បាស់លាស់តាមផ្លូវច្បាប់ និង ភស្តុតាងគ្រប់គ្រាន់ ដើម្បីកំណត់ច្បាស់ថា **ឌុច** ជាជនជាប់ចោទស្ថិតនៅក្នុងយុត្តាធិការរបស់ខ្លួននោះទេ ។

៩៤. ទាំងអស់នេះជាដើមហេតុធ្វើឱ្យអង្គជំនុំជម្រះទាំងមូលជម្រះក្តី **កាំង ហ្កេកអ៊ាវ** ហៅ **ឌុច** ដោយភាន់ច្រឡំថា **កាំង ហ្កេកអ៊ាវ** ហៅ **ឌុច** ស្ថិតនៅក្រោមយុត្តាធិការរបស់ខ្លួន ព្រមទាំងច្រានចោលសេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តីថាជា អញ្ញត្រកម្មលើកឡើងយឺតពេលទៅវិញ ។ ថ្វីត្បិតតែមេធាវីមិនបានជំទាស់ទៅនឹងសហព្រះរាជអាជ្ញានៅគ្រាដំបូងក្តី តែសហព្រះរាជអាជ្ញាក៏បានលើកឡើងជាបទចោទលើជនជាប់ចោទ ហេតុនេះវាមិនមែនជាអញ្ញត្រកម្មលើកឡើងយឺតពេលដូចសេចក្តីសម្រេចក្នុងសាលក្រមលេខ០០១/១៨-០៧-២០០៧/អវតក/អជសជ របស់អង្គជំនុំជម្រះសាលាដំបូងចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ត្រង់ចំនុចដែលលើកឡើងថា **"នៅក្នុងអំឡុងពេលសវនាការបឋម មិនមានការលើកឡើងអំពីអញ្ញត្រកម្មចំពោះយុត្តាធិការរបស់ អ.វ.ត.ត ផ្អែកតាមវិធាន៨៩ នៃវិធានផ្ទៃក្នុងទេ"**[៧៩] និងត្រង់ចំណុច **"អង្គជំនុំជម្រះមិនបានចាត់ទុកនូវសេចក្តីសន្និដ្ឋាន ដែលបានលើកឡើងមិនទាន់ពេលវេលានោះថាជាអញ្ញត្រកម្មនោះទេ ។ អង្គជំនុំជម្រះកត់សម្គាល់ថា អំណះអំណាងនេះបានលើកឡើងមិនទាន់ពេលវេលា ហេតុដូច្នេះ ត្រូវបដិសេធចោល"**[៨០]នោះទេ ។

៩៥. បើអង្គជំនុំជម្រះយល់ឃើញថា បទចោទប្រកាន់លើជនជាប់ចោទថាជាក្រុមទទួលខុសត្រូវខ្ពស់បំផុតលើឧក្រិដ្ឋកម្ម ជាអញ្ញត្រកម្មលើកឡើងយឺតពេលនោះ **តើអង្គជំនុំជម្រះសំអាងលើអ្វីខ្លះមុនពេលទទួលសំណុំរឿងលេខ០០១ ពីសហព្រះរាជអាជ្ញាប្តឹងមកនោះ** ? ហេតុនេះយើងសន្និដ្ឋានបានថា អង្គជំនុំជម្រះខ្លួនឯងបានខ្វះខាតក្នុងកិច្ចការចាំបាច់ដើម្បីពិនិត្យលើយុត្តាធិការរបស់ខ្លួន លើយុត្តាធិការបុគ្គលនៃជនជាប់ចោទមុនពេល

---

[៧៧] D3 ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ១១៤-១១៥ ។

[៧៨] D99 ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ, កថាខណ្ឌ ១២៩។

[៧៩] សាលក្រមចុះថ្ងៃទី២៦ កក្កដា ២០១០, កថាខណ្ឌ ១៤ ។

[៨០] សាលក្រមចុះថ្ងៃទី២៦ កក្កដា ២០១០, កថាខណ្ឌ ១៥ ។

ទទួលសំណុំរឿងលេខ០០១ មកជំនុំជម្រះក្តីស្របតាមមាត្រា១ នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជា-ជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ និងមាត្រា១ និងមាត្រា២(ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងវិធាន៨៧ នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ហើយប្រឆាំងទៅនឹងគោលការណ៍ច្បាប់ជាសកលក្នុងប្រព័ន្ធច្បាប់(Civil Law)ដែលថា**គ្មានច្បាប់គឺគ្មានបទឧក្រិដ្ឋ** (Nullum Crimen Sine Lege), រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជាមាត្រា៣៨ កថាខណ្ឌទី៦ ។

៩៦. ការលើកឡើងរបស់អង្គជំនុំជម្រះសាលាដំបូងត្រង់ចំណុច **"មូលដ្ឋាននៃសំអាងហេតុនេះត្រូវបានចែងខុសគ្នារវាងប្រព័ន្ធច្បាប់ (Common Law) និងព័ន្ធច្បាប់ (Civil Law) និងនៅក្នុងសំណៅភាសាផ្សេងៗគ្នានៃវិធាន៨៧(១) នៃវិធានផ្ទៃក្នុង។ ច្បាប់កម្ពុជាចេញមកពីច្បាប់ស៊ីវិល និងពិសេស ចេញពីសញ្ញាណនៃជំនឿស្មោះត្រង់ពិតប្រាកដរបស់ចៅក្រម (judge's intime conviction) ។..."**[៨១] នៃសាលក្រម ដែលប្រើប្រព័ន្ធច្បាប់ (Common Law) មកធ្វើជាប្រភពនៃច្បាប់គឺជាការរំលោភទាំងស្រុងចំពោះគ្រប់វាល់បទដ្ឋានច្បាប់កម្ពុជាដែលទទួលស្គាល់ដោយអង្គការសហប្រជាជាតិ កម្ពុជា និង អង្គជំនុំជម្រះខ្លួនឯង ដែលថាកម្ពុជាប្រើប្រព័ន្ធច្បាប់(Civil Law) តាមព្រឹត្តិហេតុ ។ ភស្តុតាងថាសាលាជម្រះក្តីសាលាដំបូងគ្មានយុត្តាធិការលើបុគ្គល **កាំង ហ្គេកអ៊ាវ** ហៅ **ឌុច** ត្រូវបានទទួលយក និងដឹងលឺដោយសហចៅក្រមជាតិ និងអន្តរជាតិដោយហេតុថា យ៉ាងហោចណាស់មានចៅក្រមអន្តរជាតិចំនួន១(មួយ)រូប[៨២]បានទទួលស្គាល់ថា អង្គជំនុំ-ជម្រះសាលាដំបូងពិតជាគ្មានយុត្តាធិការលើរូបឈ្មោះ **កាំង ហ្គេកអ៊ាវ** ហៅ **ឌុច** ទេ ។

៩៧. ផ្អែកតាមជំហរមិនច្បាស់លាស់របស់សហព្រះរាជអាជ្ញា ក៏ដូចជាភាពស្រពិចស្រពិលរបស់សហចៅក្រមស៊ើបអង្កេត និងអ្នកជំនាញផ្នែកកោសលវិច័យចិត្តសាស្ត្រ អង្គជំនុំជម្រះសាលាដំបូងមានកំហុស ដោយមិនពិចារណាលើគោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ។

---

[៨១] សាលក្រមចុះថ្ងៃទី២៦ កក្កដា ២០១០, កថាខណ្ឌ ៤៥ ។

[៨២] មតិជំទាស់របស់ចៅក្រម Jean-Marc LAVERGNE , ឯកសារ E188.1។

៩៨. វិធីសាស្ត្រដែលអង្គជំនុំជម្រះសាលាដំបូងប្រើប្រាស់សម្រាប់ដាក់បន្ទុកឲ្យជនជាប់ចោទស្ថិតក្នុងយុត្តាធិការ-របស់ អ.វ.ត.ក ពុំមានលក្ខណៈតក្កៈតាមផ្លូវច្បាប់។

៩៩. ការសម្រេចសេចក្តីរបស់អង្គជំនុំជម្រះសាលាដំបូងពុំឃើញមានសម្លេងគាំទ្រជាឯកច្ឆ័ន្ទ ។ លក្ខណៈនេះបញ្ជាក់ថាមានភាពមិនប្រក្រតីក្នុងការផ្តល់យុត្តិធម៌ជូនជនជាប់ចោទ។

## <u>*សេចក្តីសន្និដ្ឋានចុងក្រោយ ៖*</u>

១០០. សាលាជម្រះក្តី អ.វ.ត.ក មិនមានយុត្តាធិការលើរូប **កាំង ហ្កេកអ៊ាវ** ហៅ **ឌុច** ទេ តាមមាត្រា ១ នៃកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និង អង្គការសហប្រជាជាតិ ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ តាមមាត្រា១ និងមាត្រា២(ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក តាមវិធាន៨៧ នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក និងតាមគោលការណ៍ជាសកលនៃច្បាប់ក្នុងប្រព័ន្ធច្បាប់ (Civil Law) ដែលថា**គ្មានច្បាប់គ្មានបទឧក្រិដ្ឋ** (Nullum Crimen Sine Lege) ព្រោះថា ឋានៈរបស់ **ឌុច** ទាំងក្នុងជួររដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ និងបក្សកុម្មុយនីស្តកម្ពុជាគឺជាឋានៈថ្នាក់មូលដ្ឋានជាន់ទាបមិនមែនជាឋានៈជាន់ខ្ពស់ទេ។

- ហេតុនេះសាលក្រមសំណុំរឿងលេខ ០០១/១៨-០៧-២០០៧/អវតក/អជសង របស់សាលាដំបូង នៃ អ.វ.ត.ក ត្រូវចាត់ទុកជាមោឃៈ ហើយ **កាំង ហ្កេកអ៊ាវ** ហៅ **ឌុច** ត្រូវដោះលែងអោយមានសេរីភាពឡើងវិញជាធម្មតា ។

- ការឃុំខ្លួន **កាំង ហ្កេកអ៊ាវ** ហៅ **ឌុច** ពីថ្ងៃចាប់ខ្លួនរហូតដល់បច្ចុប្បន្នគួរត្រូវចាត់ទុកថាជាកិច្ចរក្សាការពារសាក្សីមានសក្តានុពល សម្រាប់ចង្អុលបង្ហាញពីមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងអ្នកទទួលខុសត្រូវខ្ពស់បំផុតលើឧក្រិដ្ឋកម្មនៅ ស-២១ ឬ គុកទួលស្លែង ។

F14

- ការជំនុំជម្រះក្តីលើសំណុំរឿងលេខ ០០១/១៨-០៧-២០០៧/អវតក/អជសង កាលពីថ្ងៃទី៣០ ខែមិនា ឆ្នាំ២០០៩ ដល់ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៩ គួរត្រូវចាត់ទុកថាជាការជំនុំជម្រះភាន់ច្រឡំលើយុត្តាធិការនៃសាលាជម្រះក្តី ចំពោះយុត្តាធិការបុគ្គល ។

## <u>សំណូមពរ</u>

១០១. **ក.** សុំចាត់ទុកសាលក្រមសំណុំរឿងលេខ ០០១/១៨-០៧-២០០៧/អ.វ.ត.ក/អ.ជ.ស.ង ជាមោឃៈ និងដោះលែង **កាំង ហ្កេកអ៊ាវ** ហៅ **ឌុច** អោយមានសេរីភាពឡើងវិញ ។

**ខ.** សុំអោយកំណត់ថា ការឃុំខ្លួន **កាំង ហ្កេកអ៊ាវ** ហៅ **ឌុច** ថាជាកិច្ចការថែរក្សាការពារសាក្សីមានសក្តានុពល សំរាប់ចង្អុលបង្ហាញពីមេដឹកនាំជាន់ខ្ពស់ និងអ្នកទទួលខុសត្រូវខ្ពស់បំផុតលើឧក្រិដ្ឋកម្ម នៅស-២១ ហៅ គុកទួលស្លែង ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ៕

## សុំរក្សាសិទ្ធិកែប្រែគ្រប់យ៉ាង

| | | | |
|---|---|---|---|
| ១៨-១១-២០១០ | សហមេធាវីជាតិ<br>មេធាវី **ការ សាវុត្ថ**<br>មេធាវី **កង ប៊ុន្នារី** | ភ្នំពេញ |  |
| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |